# مدرسة اهل البيت

صلوات الله عليهم

# សាលា
# អាស្ហ់លុល-បៃត៍

## សៀវភៅសិក្សា សីលធម៌ (أَخْلَاقٌ) ថ្នាក់ទី ៧

(អាយុ ១១-១២ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តា ﷺ មានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ច លើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ គោរពឪពុកម្ដាយ ........................................ ៥
មេរៀនទី ២ សិទ្ធិ និង កាតព្វកិច្ចចំពោះឪពុកម្ដាយ ........................................ ៨
មេរៀនទី ៣ សេចក្ដីគោរព - ភាគ ១ ........................................ ១៦
មេរៀនទី ៤ សេចក្ដីគោរព - ភាគ ២ ........................................ ១៩
មេរៀនទី ៥ សេចក្ដីគោរព - ភាគ ៣ ........................................ ២៣
មេរៀនទី ៦ របៀបស្លៀកពាក់ ........................................ ២៦
មេរៀនទី ៧ ចិត្តទូលាយ ........................................ ២៨
មេរៀនទី ៨ ដាក់ខ្លួន-រាបសា ........................................ ៣០
មេរៀនទី ៩ ការអើពើចំពោះជនខ្វះខាត ........................................ ៣៣
មេរៀនទី ១០ សេចក្ដីលោភលន់ ........................................ ៣៤
មេរៀនទី ១១ កំណាញ់ ........................................ ៣៥
មេរៀនទី ១២ ហ្វីតណាស្ទ់ និង ហ្វាសាដ្ទ់ - ការក្បត់ ........................................ ៣៧
មេរៀនទី ១៣ ឈ្នានីស និង ឥច្ឆា ........................................ ៤០
មេរៀនទី ១៤ បន្ថោកខ្លួនឯង ........................................ ៤២
មេរៀនទី ១៥ ត្អូញត្អែរពេលមានទុក្ខលំបាក - ការកម្ទេញ ........................................ ៤៤
មេរៀនទី ១៦ ដណ្ដើមយកទ្រព្យគេ - លួច ........................................ ៤៧
មេរៀនទី ១៧ គេចវេះភារកិច្ច ........................................ ៥០
មេរៀនទី ១៨ ការស្វូកប៉ាន់ - ព្រឹទ្ធិកម្ម ........................................ ៥២
មេរៀនទី ១៩ ការបោកប្រាស់ - ការគៃបន្លំ (យកទ្រព្យគេ) ........................................ ៥៥
មេរៀនទី ២០ មើលស្រ្តីនិងបុរសដែលត្រូវហាម (មិន-ម៉ាស៊្ររ៉ម) ........................................ ៥៨

## មេរៀនទី ១

# គោរពឪពុកម្ដាយ

មនុស្សធំមើលថែទាំខ្លួនឯង ។ គាត់ប្រកបកិច្ចការ រកប្រាក់ចំណូល ទិញចំណីអាហារនិងសំលៀកបំពាក់ បង់វិក័យប័ត្រ (ថ្លៃផ្ទះ, ថ្លៃភ្លើង, ថ្លៃទឹក ។ល ។) និងមើលថែទាំផ្ទះ ។

ចំណែកខ្លួនយើងវិញ ? តើយើងអាចធ្វើការរកប្រាក់ចំណូលបានទេ ? អាចទិញចំណីអាហារខ្លួនឯង បង់ថ្លៃផ្ទះខ្លួនឯងបានទេ ? យើងនៅក្មេងនៅឡើយ នៅក្រោមអាណាព្យាបាលរបស់ឪពុកម្ដាយ ។ យើងមិនអាចមើលថែទាំខ្លួនឯងបានទេ ។

យើងដឹងច្បាស់ថាឪពុកម្ដាយយើងជាអ្នកមើលថែទាំយើង និងធ្វើប្រការទាំងអស់នេះ ហេតុអ្វីលោកទទួលខុសត្រូវអ្វីៗទាំងអស់នេះ ? ព្រោះយើងជាកូនរបស់លោក ព្រោះលោកស្រឡាញ់យើង ។ លោកចង់ឲ្យយើងធាត់ធំដោយមានសុខភាពល្អនិងមានសុជីវធម៌ ។ ដូច្នេះ លោកខិតខំពុះពារគ្រប់ឧបសគ្គដើម្បីយើង ដើម្បីចិញ្ចឹមយើងឲ្យបានទៅជាមនុស្សល្អ ។ តើយើងមិនត្រូវស្រឡាញ់លោកដែរទេ តើយើងមិនត្រូវគោរពលោកនិងស្ដាប់បង្គាប់លោកទេ ?

ឪពុកម្ដាយយើងចិញ្ចឹមយើង ។ លោករស់នៅដើម្បីយើង ។ លោកស្រឡាញ់យើង ថ្នាក់ថ្នមយើង លោកបង្ហាត់ងបង្រៀនយើងឲ្យដឹងអ្វីខុសអ្វីត្រូវ លោកផ្ដល់ចំណីអាហារដល់យើង ។ ប្រសិនបើមានអាហារតិចសម្រាប់តែម្នាក់ លោកឲ្យអាហារនោះទៅកូន ។ ម្ដាយយើងពយើងក្នុងពោះអស់រយៈពេល ៩ ខែ ទាំងយប់ទាំងថ្ងៃ មុនយើងកើតមក ។

នេះគឺមូលហេតុមួយដែលអ៊ីស្លាមចែងថា៖ "ឋានសួគ៌នៅក្រោមជើងម្ដាយអ្នក ។"

បានសេចក្ដីថា បើអ្នកធ្វើឲ្យម្ដាយអ្នកក្រោធ អ្នកនឹងមិនបានចូលឋានសួគ៌ជាដាច់ខាត ពោលគឺ ផ្លូវទៅកាន់ឋានសួគ៌កាត់តាមសេចក្ដីសប្បាយចិត្តរបស់ឪពុកម្ដាយអ្នក ។ អល់ឡោះហ្ទ៏ﷻបានចែងអំពីរឿងនេះកាលព្រះអង្គﷻមានព្រះបន្ទូល

ចំពោះព្រះសាស្តាមួយអង្គរបស់ព្រះអង្គﷻថា៖ "អញﷻសូមស្បថចំពោះព្រះកិត្តិយសអញﷻថា អ្នកណាមិនគោរពឪពុកម្តាយខ្លួនទេ ទោះបីអ្នកនោះមកជួបអញﷻដោយនាំមកនូវទង្វើដូចព្រះសាស្តាក៏ដោយ ក៏អញﷻមិនព្រមទទួលទង្វើនោះដែរ ។"

នៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាន់-នីសាអ៍ អាយ៉ាស់ 36 (4:36) អល់ឡោះហ៍ﷻមានព្រះបន្ទូលថា៖

﴿وَٱعۡبُدُواْ ٱللَّهَ وَلَا تُشۡرِكُواْ بِهِۦ شَيۡـٔٗاۖ وَبِٱلۡوَٰلِدَيۡنِ إِحۡسَٰنٗا... ٣٦﴾

*36. ចូរពួកអ្នកគោរពសក្ការៈអល់ឡោះហ៍ ចូរកុំធ្វើបដិគ្គអ្វីជាមួយព្រះអង្គឡើយ ចូរប្រព្រឹត្តល្អចំពោះឪពុកម្តាយ... ។*

ព្រះអង្គﷻមានព្រះបន្ទូលប្រាប់យើងនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ បានីអ៊ីសរ៉អ៊ីល អាយ៉ាស់ 23-24 (17:23-24) ដែរថា៖

﴿وَقَضَىٰ رَبُّكَ أَلَّا تَعۡبُدُوٓاْ إِلَّآ إِيَّاهُ وَبِٱلۡوَٰلِدَيۡنِ إِحۡسَٰنًاۚ إِمَّا يَبۡلُغَنَّ عِندَكَ ٱلۡكِبَرَ أَحَدُهُمَآ أَوۡ كِلَاهُمَا فَلَا تَقُل لَّهُمَآ أُفّٖ وَلَا تَنۡهَرۡهُمَا وَقُل لَّهُمَا قَوۡلٗا كَرِيمٗا ٢٣ وَٱخۡفِضۡ لَهُمَا جَنَاحَ ٱلذُّلِّ مِنَ ٱلرَّحۡمَةِ وَقُل رَّبِّ ٱرۡحَمۡهُمَا كَمَا رَبَّيَانِي صَغِيرٗا ٢٤﴾

*23. ព្រះម្ចាស់អ្នកបានដាក់បញ្ជាថាឲ្យពួកអ្នក (មនុស្សទាំងឡាយ) គោរពបូជាតែព្រះអង្គមួយគត់ ឲ្យពួកអ្នកប្រព្រឹត្តល្អចំពោះឪពុកម្តាយពួកអ្នក ។ បើអ្នកណាម្នាក់ ឬអ្នកទាំងពីរមានវ័យជរានៅជាមួយអ្នក ចូរអ្នកកុំនិយាយស្តីថា "ថ្វីយ! (ជាពាក្យពោលចេញមក សម្តែងឲ្យឃើញថាមានការធុញទ្រាន់ រំខានឬស្អប់)" ឡើយ ចូរអ្នកកុំគំហកដាក់អ្នកទាំងពីរឡើយ ចូរអ្នកមានវាចារកពួកគេដោយប្រើសំដីល្អប្រពៃ [ដោយគោរព] ។ 24. ចូរអ្នកបន្ទាបស្លាបនៃសេចក្តីគោរពចំពោះអ្នកទាំងពីរ ដោយមានចិត្តធម៌[និងប្រោសប្រណី] ហើយចូរអ្នកពោលថា៖ "ព្រះម្ចាស់អើយ សូមព្រះអង្គមានព្រះមេត្តាធម៌ដល់លោកទាំងពីរ ឲ្យដូចកាលដែលលោកទាំងពីរបានចិញ្ចឹមទូលព្រះបង្គំជាខ្ញុំកាលពីតូចផង ។"*

ហេតុអ្វីព្រះគម្ពីរគួរអានថៃងអំពីឪពុកម្តាយច្រើនដងម្ល៉េះ ?

ពីព្រោះឪពុកម្តាយមានតួនាទីសំខាន់ណាស់នៅក្នុងការអប់រំកូនៗ ។ ព្រះសាស្តាមូហាំម៉ាដ្ឋﷺមានព្រះវចនៈថា៖ "កូនៗនៅក្រោមបន្ទុកទទួលខុសត្រូវរបស់ឪពុកម្តាយដូចឪពុកម្តាយនៅក្នុងបន្ទុកទទួលខុសត្រូវរបស់កូនៗដែរ ។"

អល់ឡោះហ៍ تَعَالَى وَ سُبْحَانَهُ ប្រសិទ្ធពរជ័យដល់បណ្តាអ្នកដែលណែនាំកូនខ្លួនឲ្យប្រព្រឹត្តអំពើល្អដែលខ្លួនឯងធ្វើដែរ ។ អ៊ីស្លាមចាត់ទុកការអប់រំនៅក្នុងវ័យក្មេងជាប្រការសំខាន់ណាស់ព្រោះអាត្ម័នក្មេងៗត្រៀមចាំទទួលសព្វសារពើ ។

អ៊ីម៉ាំអាលី عليه السلام صلوات الله មានវចនៈថា៖ "អ្វីៗដែលគេបង្ហាត់ឲ្យក្មេងៗចេះដឹងត្រូវចារទុកជាប់នៅក្នុងចិត្តវាដូចចំណារនៅលើផ្ទាំងថ្ម ។"

ឌូអាអ៍មួយដកស្រង់ពីព្រះគម្ពីរគួរអាន (17:24) សម្រាប់បួងសួងអល់ឡោះហ៍ عزّ وجلّ ឲ្យឪពុកម្តាយ គឺ៖

رَّبِّ ٱرْحَمْهُمَا كَمَا رَبَّيَانِى صَغِيرًا ﴿٢٤﴾

រ៉ប់បៀរហ៊ាំហ៊ូម៉ា កាម៉ា រ៉ប់បាយ៉ានី ស្វ៊ហ្គីរ៉

*24. ... "ព្រះម្ចាស់អើយ សូមព្រះអង្គមានព្រះមេត្តាធម៌ដល់លោកទាំងពីរ ឲ្យដូចកាលដែលលោកទាំងពីរបានចិញ្ចឹមទូលព្រះបង្គំជាខ្ញុំកាលពីតូចផង ។"*

## មេរៀនទី ២

# សិទ្ធិ និង កាតព្វកិច្ចចំពោះឪពុកម្តាយ

មានរបៀបច្រើនសម្រាប់គោរពឪពុកម្តាយអ្នក ។ ដូចជា ៖

☺ និយាយផ្អែមល្ហែមជាមួយលោក ។

☹ កុំនិយាយសម្លេងខ្លាំងជាងសម្លេងលោក ។

☺ ចិញ្ចឹមលោក ។

☺ អរគុណលោកនិងបួងសួងអល់ឡោះហ៏ﷻឲ្យលោក ។

☹ កុំអង្គុយពេលលោកឈរ ។

☹ កុំដើរពីមុខលោក លើកលែងតែលោកអនុញ្ញាត ។

☹ កុំនិយាយពេលលោកនិយាយ ។

☹ កុំនិយាយប្រឆាំងលោកនៅពីមុខអ្នកដទៃ ។

☹ កុំធ្វើឲ្យលោកមិនសប្បាយចិត្តឬក្រោធ ។

☹ កុំជេរប្រមាថលោក កុំតវ៉ាឬកុំស្រែកដាក់លោកជាដាច់ខាត ។

☹ កុំធ្វើឲ្យលោកឈឺចាប់ ទោះបីលោកមិនមែនមុស្លីមក៏ដោយ ។

ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ មានព្រះវចនៈថា៖ "អ្នកណាធ្វើឲ្យឪពុកម្តាយឈឺចាប់ អ្នកនោះធ្វើឲ្យខ្ញុំ ﷺ ឈឺចាប់ អ្នកណាធ្វើឲ្យខ្ញុំ ﷺ ឈឺចាប់ អ្នកនោះធ្វើឲ្យអល់ឡោះហ៏ﷻឈឺចាប់ អ្នកណាធ្វើឲ្យអល់ឡោះហ៏ﷻឈឺចាប់ អ្នកនោះត្រូវបណ្តាសាក្នុងព្រះគម្ពីរតៅរ៉ត្ត ក្នុងព្រះគម្ពីរអ៊ីនយ៉ីល ក្នុងព្រះគម្ពីរស្សាប៊ូរ និងក្នុងព្រះគម្ពីរគួរអាន ។"

ពេលព្រឹក ពេលអ្នកងើបពីដេក ប្រការដំបូងបង្អស់ដែលអ្នកត្រូវធ្វើគឺឲ្យសាឡាមឪពុកម្តាយទាំងពីរថា៖ "អាស់សាឡាមូ អាឡៃគុម" ។

បើឪពុកម្តាយអ្នកប្រើអ្នកធ្វើអ្វីមួយដូចជាទៅផ្សារទិញអ៊ីវ៉ាន់ជាដើម អ្នកមិនត្រូវប្រកែកឡើយ សូម្បីតែដោយយកលេសថាអ្នកអស់កម្លាំងក៏ដោយ ។ អ្នកមិន

ត្រូវសម្លឹងមុខឪពុកម្តាយដោយទឹកមុខធុញទ្រាន់ឡើយដែរ ។

ហេតុដូច្នេះឯងបានជាគេថា៖ "ចូរមើលមុខឪពុកម្តាយខ្លួនដោយសេចក្តីគោរពប្រៀបបាននឹងមើលកាក់ុបាស់ុ គឺបានរង្វាន់ស្មើគ្នា ។"

## កិច្ចការផ្ទះ

ខាងក្រោមនេះគឺឌូអាុអ៍ដែលអ៊ីមុាំទី ៤ របស់យើង អ៊ីមុាំ អាស់-សាច់យ៉ាដ្ុំ អាុលី ស្ហែនុល-អាុប៊ីឌីន صلوات الله عليه والسلام បង្ហាត់យើង ដកស្រង់ពីកម្រងឌូអាុអ៍របស់ព្រះអង្គ صلوات الله عليه والسلام អាស្ុ-ស្ហ៊ីហ្វាស់ុ អាល់-កាមីឡាស់ុ អាស់-សាច់យ៉ាដ្ីយ៉ាស់ុ (اَلصَّحيفَةُ الْكامِلَةُ السَّجّادِيَّةُ) ។

កិច្ចការរបស់អ្នកគឺ សូត្រឌូអាុអ៍នេះរាល់យប់ឲ្យឪពុកម្តាយស្តាប់មួយអាទិត្យ ។ លោកទាំងពីរនឹងចុះហត្ថលេខាលើបញ្ជីខាងក្រោមនេះ បញ្ជាក់ថាអ្នកបានសូត្រឌូអាុអ៍ ។

وَ كَانَ مِنْ دُعَائِهِ عَلَيْهِ السَّلَامُ لِأَبَوَيْهِ عَلَيْهِمَا السَّلَامُ

بِسْمِ اللهِ الرَّحْمنِ الرَّحيمِ

1. اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ عَبْدِكَ وَ رَسُولِكَ ، وَ أَهْلِ بَيْتِهِ الطَّاهِرِينَ ، وَ اخْصُصْهُمْ بِأَفْضَلِ صَلَوَاتِكَ وَ رَحْمَتِكَ وَ بَرَكَاتِكَ وَ سَلَامِكَ .

2. وَ اخْصُصِ اللَّهُمَّ وَالِدَيَّ بِالْكَرَامَةِ لَدَيْكَ ، وَ الصَّلَاةِ مِنْكَ ، يَا أَرْحَمَ الرَّاحِمِينَ .

3. اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِهِ ، وَ أَلْهِمْنِي عِلْمَ مَا يَجِبُ لَهُمَا عَلَيَّ إِلْهَاماً ، وَ اجْمَعْ لِي عِلْمَ ذَلِكَ كُلِّهِ تَمَاماً ، ثُمَّ اسْتَعْمِلْنِي بِمَا تُلْهِمُنِي مِنْهُ ، وَ وَفِّقْنِي لِلنُّفُوذِ فِيمَا تُبَصِّرُنِي مِنْ عِلْمِهِ حَتَّى لَا يَفُوتَنِي اسْتِعْمَالُ شَيْءٍ عَلَّمْتَنِيهِ ، وَ لَا تَثْقُلَ أَرْكَانِي عَنِ الْحُفُوفِ فِيمَا أَلْهَمْتَنِيهِ .

4. اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِهِ كَمَا شَرَّفْتَنَا بِهِ ، وَ صَلِّ عَلَى مُحَمَّدٍ وَ آلِهِ ، كَمَا أَوْجَبْتَ لَنَا الْحَقَّ عَلَى الْخَلْقِ بِسَبَبِهِ.

5. اللَّهُمَّ اجْعَلْنِي أَهَابُهُمَا هَيْبَةَ السُّلْطَانِ الْعَسُوفِ ، وَ أَبَرُّهُمَا بِرَّ الْأُمِّ الرَّءُوفِ ، وَ اجْعَلْ طَاعَتِي لِوَالِدَيَّ وَ بِرِّي بِهِمَا أَقَرَّ لِعَيْنِي مِنْ رَقْدَةِ الْوَسْنَانِ ، وَ أَثْلَجَ لِصَدْرِي مِنْ شَرْبَةِ الظَّمْآنِ حَتَّى أُوثِرَ عَلَى هَوَايَ هَوَاهُمَا ، وَ أُقَدِّمَ عَلَى رِضَايَ رِضَاهُمَا وَ

أَسْتَكْثِرَ بِرَّهُمَا بِي وَ إِنْ قَلَّ ، وَ أَسْتَقِلَّ بِرِّي بِهِمَا وَ إِنْ كَثُرَ .

6. اللَّهُمَّ خَفِّضْ لَهُمَا صَوْتِي ، وَ أَطِبْ لَهُمَا كَلَامِي ، وَ أَلِنْ لَهُمَا عَرِيكَتِي ، وَ اعْطِفْ عَلَيْهِمَا قَلْبِي ، وَ صَيِّرْنِي بِهِمَا رَفِيقاً ، وَ عَلَيْهِمَا شَفِيقاً .

7. اللَّهُمَّ اشْكُرْ لَهُمَا تَرْبِيَتِي ، وَ أَثِبْهُمَا عَلَى تَكْرِمَتِي ، وَ احْفَظْ لَهُمَا مَا حَفِظَاهُ مِنِّي فِي صِغَرِي .

8. اللَّهُمَّ وَ مَا مَسَّهُمَا مِنِّي مِنْ أَذًى ، أَوْ خَلَصَ إِلَيْهِمَا عَنِّي مِنْ مَكْرُوهٍ ، أَوْ ضَاعَ قِبَلِي لَهُمَا مِنْ حَقٍّ فَاجْعَلْهُ حِطَّةً لِذُنُوبِهِمَا ، وَ عُلُوّاً فِي دَرَجَاتِهِمَا ، وَ زِيَادَةً فِي حَسَنَاتِهِمَا ، يَا مُبَدِّلَ السَّيِّئَاتِ بِأَضْعَافِهَا مِنَ الْحَسَنَاتِ .

9. اللَّهُمَّ وَ مَا تَعَدَّيَا عَلَيَّ فِيهِ مِنْ قَوْلٍ ، أَوْ أَسْرَفَا عَلَيَّ فِيهِ مِنْ فِعْلٍ ، أَوْ ضَيَّعَاهُ لِي مِنْ حَقٍّ ، أَوْ قَصَّرَا بِي عَنْهُ مِنْ وَاجِبٍ فَقَدْ وَهَبْتُهُ لَهُمَا ، وَ جُدْتُ بِهِ عَلَيْهِمَا وَ رَغِبْتُ إِلَيْكَ فِي وَضْعِ تَبِعَتِهِ عَنْهُمَا ، فَإِنِّي لَا أَتَّهِمُهُمَا عَلَى نَفْسِي، وَ لَا أَسْتَبْطِئُهُمَا فِي بِرِّي ، وَ لَا أَكْرَهُ مَا تَوَلَّيَاهُ مِنْ أَمْرِي يَا رَبِّ .

10. فَهُمَا أَوْجَبُ حَقّاً عَلَيَّ ، وَ أَقْدَمُ إِحْسَاناً إِلَيَّ ، وَ أَعْظَمُ مِنَّةً لَدَيَّ مِنْ أَنْ أُقَاصَّهُمَا بِعَدْلٍ ، أَوْ أُجَازِيَهُمَا عَلَى مِثْلٍ ، أَيْنَ إِذاً يَا إِلَهِي طُولُ شُغْلِهِمَا بِتَرْبِيَتِي وَ أَيْنَ شِدَّةُ تَعَبِهِمَا فِي حِرَاسَتِي وَ أَيْنَ إِقْتَارُهُمَا عَلَى أَنْفُسِهِمَا لِلتَّوْسِعَةِ عَلَيَّ؟

11. هَيْهَاتَ مَا يَسْتَوْفِيَانِ مِنِّي حَقَّهُمَا ، وَ لَا أُدْرِكُ مَا يَجِبُ عَلَيَّ لَهُمَا ، وَ لَا أَنَا بِقَاضٍ وَظِيفَةَ خِدْمَتِهِمَا ، فَصَلِّ عَلَى مُحَمَّدٍ وَ آلِهِ ، وَ أَعِنِّي يَا خَيْرَ مَنِ اسْتُعِينَ بِهِ ، وَ وَفِّقْنِي يَا أَهْدَى مَنْ رُغِبَ إِلَيْهِ ، وَ لَا تَجْعَلْنِي فِي أَهْلِ الْعُقُوقِ لِلْآبَاءِ وَ الْأُمَّهَاتِ يَوْمَ تُجْزَى كُلُّ نَفْسٍ بِمَا كَسَبَتْ وَ هُمْ لَا يُظْلَمُونَ.

2. اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِهِ وَ ذُرِّيَّتِهِ ، وَ اخْصُصْ أَبَوَيَّ بِأَفْضَلِ مَا خَصَصْتَ بِهِ آبَاءَ عِبَادِكَ الْمُؤْمِنِينَ وَ أُمَّهَاتِهِمْ ، يَا أَرْحَمَ الرَّاحِمِينَ.

13. اللَّهُمَّ لَا تُنْسِنِي ذِكْرَهُمَا فِي أَدْبَارِ صَلَوَاتِي ، وَ فِي إِنًى مِنْ آنَاءِ لَيْلِي ، وَ فِي كُلِّ سَاعَةٍ مِنْ سَاعَاتِ نَهَارِي.

14. اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِهِ ، وَ اغْفِرْ لِي بِدُعَائِي لَهُمَا ، وَ اغْفِرْ لَهُمَا بِبِرِّهِمَا بِي مَغْفِرَةً حَتْماً ، وَ ارْضَ عَنْهُمَا بِشَفَاعَتِي لَهُمَا رِضًى عَزْماً ، وَ بَلِّغْهُمَا بِالْكَرَامَةِ مَوَاطِنَ السَّلَامَةِ.

15. اللَّهُمَّ وَ إِنْ سَبَقَتْ مَغْفِرَتُكَ لَهُمَا فَشَفِّعْهُمَا فِيَّ ، وَ إِنْ سَبَقَتْ مَغْفِرَتُكَ لِي فَشَفِّعْنِي فِيهِمَا حَتَّى نَجْتَمِعَ بِرَأْفَتِكَ فِي دَارِ كَرَامَتِكَ وَ مَحَلِّ مَغْفِرَتِكَ وَ رَحْمَتِكَ ، إِنَّكَ ذُو الْفَضْلِ الْعَظِيمِ ، وَ الْمَنِّ الْقَدِيمِ ، وَ أَنْتَ أَرْحَمُ الرَّاحِمِينَ .

## ឌួអារ៉ុរបស់ព្រះអង្គ صلوات الله عليه والسلام សម្រាប់ព្រះមាតាបិតាទាំងពីររបស់ព្រះអង្គ عليهم السلام

ដោយនូវព្រះនាមអល់ឡោះហ្ទ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។

1. អល់ឡោះហ្ទ៍ عز وجل អឺយ សូមព្រះអង្គ عز وجل ព្រះរាជទានពរជ័យសិរីសួស្តី ដល់ មូហាំម៉ាដ់ صلى الله عليه وآله وسلم ព្រះរាជបម្រើរបស់ព្រះអង្គ عز وجل ព្រះសាសនៈទូតរបស់ព្រះអង្គ عز وجل និង

ព្រះរាជកុលដ្ឋានបរិសុទ្ធជ្រះថ្លាទាំងឡាយរបស់ព្រះអង្គﷺ ។ សូមព្រះអង្គ﷿លើកតម្កើងជាពិសេស ព្រះសន្តបុគ្គលទាំងអស់នេះ ដោយព្រះគុណូបការ ព្រះគុណ ព្រះមេត្តានិងព្រះពរព្រះអង្គ﷿ ។

2. សូមព្រះអង្គ﷿លើកតម្កើងដាច់គេមាតាបិតាទូលព្រះបង្គំជាខ្ញុំ ឱអល់ឡោះហ៍﷿អឺយ ដោយឧត្តមភាពចំពោះព្រះអង្គ﷿និងដោយព្រះករុណាពីព្រះអង្គ﷿ ឱព្រះដ៏មានព្រះមេត្តាករុណាប្រណីអឺយ ។

3. អល់ឡោះហ៍﷿អឺយ សូមព្រះអង្គ﷿ប្រទានពរជ័យសិរីសួស្តីដល់មូហាំម៉ាដ់ﷺ និងព្រះរាជវង្សព្រះអង្គﷺ ។ សូមព្រះអង្គ﷿បណ្តុះចិត្តទូលព្រះបង្គំជាខ្ញុំឲ្យដឹងករណីយកិច្ចចំពោះព្រះមាតាបិតាទូលព្រះបង្គំជាខ្ញុំ ។ សូមព្រះអង្គ﷿ឲ្យទូលព្រះបង្គំជាខ្ញុំចេះដឹងករណីយកិច្ចនេះសព្វគ្រប់ ។ សូមព្រះអង្គ﷿ឲ្យទូលព្រះបង្គំជាខ្ញុំអនុវត្តស្របតាមអ្វីដែលព្រះអង្គ﷿បានបណ្តុះចិត្តទូលព្រះបង្គំជាខ្ញុំឲ្យដឹងនោះ ។ សូមព្រះអង្គ﷿ធ្វើឲ្យទូលព្រះបង្គំជាខ្ញុំអនុវត្តបានសម្រេចនូវចំណោះ ដែលព្រះអង្គ﷿បានបង្ហាត់ទូលព្រះបង្គំជាខ្ញុំ ក្រែងលោទូលព្រះបង្គំជាខ្ញុំខកខានធ្វើតាមអ្វីដែលព្រះអង្គ﷿បានបង្ហាត់ទូលព្រះបង្គំជាខ្ញុំ ។ សូមព្រះអង្គ﷿កុំធ្វើឲ្យអវយវៈទូលព្រះបង្គំជាខ្ញុំទៅជាធ្ងន់ ដើម្បីនឹងកុំឲ្យទូលព្រះបង្គំជាខ្ញុំភ្លេចអនុវត្តអ្វីដែលព្រះអង្គ﷿បានបើកឲ្យទូលព្រះបង្គំជាខ្ញុំដឹងនោះ ។

4. អល់ឡោះហ៍﷿អឺយ សូមព្រះអង្គ﷿ប្រទានពរជ័យសិរីសួស្តីដល់មូហាំម៉ាដ់ﷺ និងព្រះរាជវង្សព្រះអង្គﷺ ។ ព្រះអង្គ﷿លើកស្ទួយអស់ទូលព្រះបង្គំជាខ្ញុំតាមរយៈព្រះអង្គﷺ ។ សូមព្រះអង្គ﷿ប្រទានពរជ័យសិរីសួស្តីដល់មូហាំម៉ាដ់ﷺនិងព្រះរាជវង្សព្រះអង្គﷺ ព្រោះព្រះអង្គ﷿ឲ្យអស់ទូលព្រះបង្គំជាខ្ញុំមានសិទ្ធិលើសត្វលោករបស់ព្រះអង្គ﷿អាស្រ័យព្រះអង្គﷺ ។

5. អល់ឡោះហ៍﷿អឺយ សូមព្រះអង្គ﷿ធ្វើឲ្យទូលព្រះបង្គំជាខ្ញុំខ្លាចព្រះមាតាបិតារបស់ទូលព្រះបង្គំជាខ្ញុំ ដូចគេខ្លាចស្តេចកាច សូមឲ្យទូលព្រះបង្គំជាខ្ញុំស្រឡាញ់ព្រះមាតាបិតាទូលព្រះបង្គំជាខ្ញុំ ដោយសេចក្តីស្រឡាញ់របស់មាតាដែលមានមេត្តា

ករុណា ។ សូមព្រះអង្គ ﷻ ធ្វើឲ្យសេចក្តីគោរពនិងសេចក្តីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំចំពោះមាតាបិតាទូលព្រះបង្គំជាខ្ញុំ ស្រទន់សម្រាប់ទូលព្រះបង្គំជាខ្ញុំជាងដំណេកសម្រាប់អ្នកងុយដេក ត្រជាក់សម្រាប់ទ្រូងទូលព្រះបង្គំជាខ្ញុំជាងទឹកសម្រាប់អ្នកស្រេក ដើម្បីបំពេញបំណងលោកទាំងពីរមុនបំណងខ្លួនឯង ដើម្បីបំពេញសេចក្តីត្រូវការរបស់លោកទាំងពីរ មុនបំពេញសេចក្តីត្រូវការរបស់ខ្លួនឯង ។

6. អល់ឡោះហ្ ﷻ អើយ សូមព្រះអង្គ ﷻ បន្ទាបសម្លេងទូលព្រះបង្គំជាខ្ញុំដាក់លោកទាំងពីរ សូមព្រះអង្គ ﷻ ធ្វើឲ្យសម្តីទូលព្រះបង្គំជាខ្ញុំពីរោះសម្រាប់លោកទាំងពីរ ។ សូមព្រះអង្គ ﷻ ធ្វើឲ្យអារម្មណ៍ទូលព្រះបង្គំជាខ្ញុំត្រជាក់ដាក់លោកទាំងពីរ សូមព្រះអង្គ ﷻ ធ្វើឲ្យចិត្តទូលព្រះបង្គំជាខ្ញុំទន់ដាក់លោកទាំងពីរ សូមព្រះអង្គ ﷻ ធ្វើឲ្យទូលព្រះបង្គំជាខ្ញុំទៅជាកនល្អនិងមិត្តជាស្រឡាញ់របស់លោកទាំងពីរ ។

7. អល់ឡោះហ្ ﷻ អើយ សូមព្រះអង្គ ﷻ អរគុណលោកទាំងពីរដែលបានចិញ្ចឹមទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គ ﷻ តបស្នងលោកទាំងពីរដែលបានស្រឡាញ់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គ ﷻ ការពារលោកទាំងពីរដូចលោកទាំងពីរបានការពារទូលព្រះបង្គំជាខ្ញុំ កាលទូលព្រះបង្គំជាខ្ញុំនៅក្មេង ។

8. អល់ឡោះហ្ ﷻ អើយ បើលោកទាំងពីរអន់ចិត្តដោយសារទូលព្រះបង្គំជាខ្ញុំ បើទូលព្រះបង្គំជាខ្ញុំធ្វើឲ្យលោកទាំងពីរមិនពេញចិត្ត ឬបើទូលព្រះបង្គំជាខ្ញុំមិនបានបំពេញករណីយកិច្ចចំពោះលោកទាំងពីរទេ សូមឲ្យកំហុសទាំងនេះទៅជាការលើកលែងទោសសម្រាប់លោកទាំងពីរ ទៅជាការលើកឋានៈសម្រាប់លោកទាំងពីរ ទៅជាការបង្កើនទង្វើល្អសម្រាប់លោកទាំងពីរ ឱព្រះដែលប្តូរទង្វើអាក្រក់ជាទង្វើល្អដ៏ច្រើន ។

9. អល់ឡោះហ្ ﷻ អើយ ទូលព្រះបង្គំជាខ្ញុំលើកទោសឲ្យលោកទាំងពីរដោយស្មោះអស់ពីចិត្តដែលបានប្រព្រឹត្តបំពានឬជ្រុលលើទូលព្រះបង្គំជាខ្ញុំ ឬដែលបំពានសិទ្ធិទូលព្រះបង្គំជាខ្ញុំ ឬដែលមិនបំពេញករណីយកិច្ចខ្លួនចំពោះទូលព្រះបង្គំជាខ្ញុំ ។ ទូលព្រះបង្គំជាខ្ញុំ សូមឲ្យព្រះអង្គ ﷻ លើកទោសឲ្យលោកទាំងពីរដែលបានធ្វើខុសព្រោះទូលព្រះបង្គំជាខ្ញុំមិនចោទបង្អាច់លោកទាំងពីរទេ ថាធ្វើឲ្យទូលព្រះបង្គំជាខ្ញុំ

ឈឺចាប់ ទូលព្រះបង្គំជាខ្ញុំក៏មិនគិតទេថាលោកទាំងពីរខ្វះសីលធម៌ចំពោះទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំក៏មិនស្អប់ការថែទាំទូលព្រះបង្គំជាខ្ញុំរបស់លោកទាំងពីរទេដែរ ឱព្រះﷻអើយ ។

10. សិទ្ធិរបស់លោកទាំងពីរលើខ្លួនទូលព្រះបង្គំជាខ្ញុំធំណាស់ លោកទាំងពីរមានគុណធំណាស់មកលើទូលព្រះបង្គំជាខ្ញុំ លោកទាំងពីរមានចិត្តល្អប្រពៃណាស់ចំពោះទូលព្រះបង្គំ ទូលព្រះជាខ្ញុំមិនអាចទូទាត់ឬតបស្នងលោកទាំងពីរបានឡើយ ។ ឱព្រះﷻទូលព្រះបង្គំជាខ្ញុំអើយ តើឲ្យទូលព្រះបង្គំជាខ្ញុំសងលោកទាំងពីរបានដូចម្តេចទៅ ដែលលោកបានចិញ្ចឹមទូលព្រះបង្គំជាខ្ញុំយ៉ាងលំបាក ដែលបានថែរក្សាទូលព្រះបង្គំជាខ្ញុំដោយយកចិត្តទុកដាក់បំផុត ដែលបានលះបង់សព្វបែបយ៉ាងដើម្បីផ្គត់ផ្គង់ទូលព្រះបង្គំជាខ្ញុំមិនឲ្យខ្វះខាតឡើយ ?

11. អកុសល ទូលព្រះបង្គំជាខ្ញុំមិនអាចសងព្រះគុណលោកទាំងពីរបានឡើយ ទូលព្រះបង្គំជាខ្ញុំមិនអាចបំពេញករណីយកិច្ចសងលោកទាំងពីរវិញបានឡើយ មិនអាចបំពេញភារកិច្ចបម្រើលោកទាំងពីរឲ្យគ្រប់គ្រាន់សងវិញបានឡើយ ។ ដូច្នេះ សូមព្រះអង្គﷻព្រះរាជទានពរជ័យសិរីសួស្តីឲ្យមូហាំម៉ាដ់ﷻ និងព្រះរាជកុលដ្ឋានعليهم السلامព្រះអង្គﷺ ។ សូមព្រះអង្គﷻជួយទូលព្រះបង្គំជាខ្ញុំផង ឱព្រះអ្នកជួយសង្គ្រោះដ៏ប្រសើរដាច់គេអើយដែលអស់ទូលព្រះបង្គំជាខ្ញុំសូមជំនួយ ។ សូមព្រះអង្គﷻឲ្យទូលព្រះបង្គំជាខ្ញុំបានសម្រេចផង ឱព្រះអ្នកដឹកនាំប្រសើរដាច់គេអើយដែលសត្វលោកអង្វរករ ។ សូមព្រះអង្គﷻកុំឲ្យទូលព្រះបង្គំជាខ្ញុំនៅក្នុងចំណោមកូនអកតញ្ញូមាតាបិតាឡើយ ថ្ងៃដែលម្នាក់ៗនឹងត្រូវតបស្នងតាមអំពើដែលខ្លួនបានសាង មិនត្រូវកេងបំបាត់ឡើយ ។

12. អល់ឡោះហ្ម៍ﷻអើយ សូមព្រះអង្គﷻព្រះរាជទានពរជ័យសិរីសួស្តីឲ្យមូហាំម៉ាដ់ﷻ និងព្រះរាជកុលដ្ឋានعليهم السلامព្រះអង្គﷺ ។ សូមព្រះអង្គﷻលើកតម្កើងដាច់គេមាតាបិតាទូលព្រះបង្គំជាខ្ញុំ ដោយការលើកតម្កើងដាច់គេដ៏ប្រសើរបំផុតដែលព្រះអង្គﷻព្រះរាជទានឲ្យបណ្តាមាតាបិតារបស់បណ្តាបាវមានសទ្ធាសិប់ចិត្តរបស់ព្រះអង្គﷻ ឱព្រះដ៏មានព្រះធម៌មេត្តាអើយ ។

13. អល់ឡោះហ៍عز وجلអឺយ សូមព្រះអង្គعز وجلកុំឲ្យទូលព្រះបង្គំជាខ្ញុំភ្លេចនឹកដល់លោកទាំងពីរក្រោយស្ងំឡាត់ទូលព្រះបង្គំជាខ្ញុំ គ្រប់ពេលវេលាក្នុងពេលយប់និងគ្រប់ពេលវេលាក្នុងពេលថ្ងៃ ។

14. អល់ឡោះហ៍عز وجلអឺយ សូមព្រះអង្គعز وجلព្រះរាជទានពរជ័យសិរីសួស្តីឲ្យមូហាំម៉ាដ់عز وجل និងព្រះរាជកុលដ្ឋានعليهم السلامព្រះអង្គصلى الله عليه وآله وسلم ។ សូមព្រះអង្គعز وجلលើកទោសឲ្យទូលព្រះបង្គំជាខ្ញុំតាមរយៈការបួងសួងរបស់ទូលព្រះបង្គំជាខ្ញុំឲ្យមាតាបិតាទូលព្រះបង្គំជាខ្ញុំ ។ សូមព្រះអង្គعز وجلលើកទោសពៃរ៍ទាំងអស់ឲ្យលោកទាំងពីរ ដែលមានចិត្តបុណ្យចំពោះទូលព្រះបង្គំជាខ្ញុំ ។ សូមព្រះអង្គعز وجلសព្វព្រះហឫទ័យលោកទាំងពីរអនេកតាមរយៈអន្តរាគាមន៍របស់ទូលព្រះបង្គំជាខ្ញុំឲ្យលោកទាំងពីរ សូមព្រះអង្គعز وجلឲ្យលោកទាំងពីរបានដល់ជម្រកផុតភ័យ អាស្រ័យព្រះហឫទ័យដ៏ទូលំទូលាយរបស់ព្រះអង្គعز وجل ។

15. អល់ឡោះហ៍عز وجلអឺយ បើព្រះអង្គعز وجلលើកទោសឲ្យលោកទាំងពីរមុនព្រះអង្គعز وجلឲ្យការបួងសួងរបស់ទូលព្រះបង្គំជាខ្ញុំបានសម្រេចដូចបំណង សូមព្រះអង្គعز وجلយកលោកទាំងពីរជាអ្នកធ្វើអន្តរាគមន៍ឲ្យទូលព្រះបង្គំជាខ្ញុំ ។ បើព្រះអង្គعز وجلលើកទោសឲ្យទូលព្រះបង្គំជាខ្ញុំមុន [ព្រះអង្គعز وجلលើកទោសឲ្យលោកទាំងពីរ] សូមព្រះអង្គعز وجل យកទូលព្រះបង្គំជាខ្ញុំជាអ្នកធ្វើអន្តរាគមន៍ឲ្យលោកទាំងពីរ ដើម្បីទូលព្រះបង្គំទាំងអស់គ្នានឹងបាននៅជុំគ្នាឯទីកន្លែងដែលព្រះអង្គعز وجلទ្រង់អនុគ្រោះឲ្យ អាស្រ័យព្រះករុណាប្រណីរបស់ព្រះអង្គعز وجل ។ ការពិត ព្រះអង្គعز وجلសម្បូរដោយព្រះសប្បុរសធម៌ ព្រះអង្គعز وجلប្រកបដោយព្រះហឫទ័យទូលំទូលាយមហិមា ព្រះអង្គعز وجلប្រកបដោយព្រះធម៌មេត្តាលើសអស់អ្នកមានធម៌មេត្តា ។

| ថ្ងៃ | ហត្ថលេខា |
| --- | --- |
| អាទិត្យ | |
| ចន្ទ | |
| អង្គារ | |
| ពុធ | |
| ព្រហស្បតិ៍ | |
| សុក្រ | |
| សៅរ៍ | |

## មេរៀនទី ៣

# សេចក្តីគោរព - ភាគ ១

ប្រព្រឹត្តចំពោះអ្នកណាមួយដោយសេចក្តីគោរពបានសេចក្តីថា ប្រព្រឹត្តចំពោះអ្នកនោះដោយលំអុតលំឱននិងដោយយកចិត្តទុកដាក់ ។ ក្នុងសាសនាអ៊ីស្លាម សេចក្តីគោរពជាមូលដ្ឋានមួយរបស់ជំនឿនិងជាសសរកន្លោងមួយរបស់សីលធម៌ ។

គេគប្បីគោរពអ្វីៗសព្វគ្រប់ ព្រោះសព្វសារពើត្រូវបង្កើតមកដោយមានគោលដៅ គោលដៅនេះឯងដែលយើងគប្បីគោរព ។

ថ្ងៃមួយអល់ឡោះហ្ស៊ ﷻ បានឲ្យព្រះសាស្តាមួយអង្គរបស់ព្រះអង្គ ﷻ ដើររកសត្វលោកមួយណាដែលអាក្រក់ជាងគេ ឥតប្រយោជន៍បំផុតនៅក្នុងលោក ។ ព្រះសាស្តាក៏បានដើររក ព្រះអង្គបានឃើញសត្វលោកច្រើន តែទីបំផុតព្រះអង្គបានឃើញឆ្កែមួយ ។ ឆ្កែនោះចាស់ ពិការ ចៃពេញខ្លួន មានអាការគួរឲ្យខ្លាច ។ ព្រះអង្គមើលទៅឆ្កែនោះ ទូលអល់ឡោះហ្ស៊ ﷻ ថា អល់ឡោះហ្ស៊ ﷻ អើយ ទូលព្រះបង្គំជាខ្ញុំបានដើរសព្វទីកន្លែង បានឃើញអ្វីៗច្រើនដែលគួរឲ្យខ្លាច តែឆ្កែមួយនេះអាក្រក់បំផុត ។ អល់ឡោះហ្ស៊ ﷻ អើយ ទោះបីក្រោយពីបានឃើញឆ្កែនេះក៏ដោយ ក៏ទូលព្រះបង្គំជាខ្ញុំមិនយល់ដែរថា ហេតុអ្វីព្រះអង្គ ﷻ ឲ្យទូលព្រះបង្គំជាខ្ញុំដើររកសត្វលោកឥតប្រយោជន៍នោះ ពីព្រោះ ឲ្យទូលព្រះបង្គំជាខ្ញុំហៅអ្វីដែលព្រះអង្គ ﷻ បានបង្កើតនោះថាឥតប្រយោជន៍បានដូចម្តេចទៅ ?

អល់ឡោះហ្ស៊ ﷻ បានប្រាប់ព្រះអង្គថា នេះគឺមេរៀនដែលព្រះអង្គ ﷻ ចង់ឲ្យព្រះសាស្តាសិក្សា ។

នៅលើឌីយ៉ាក្រាមខាងក្រោមនេះ យើងឃើញមានសេចក្តីគោរពច្រើនប្រភេទ ។

**អល់ឡោះហ៍ﷻ**

ម៉ាស់ជិដ អាស្វ៍លុល-បៃត៍ عليهم السلام

មនុស្សចាស់ ឪពុកម្តាយ

ម៉ាយ៉ាលិស លោកគ្រូ/អ្នកគ្រូ

បងប្អូនកោដ្ឋអ៊ីស្លាម ច្បាប់ស្វារីអ៊ុស្វ

**សេចក្តីគោរព**

អ្នកជិតខាង អាស្ទាន

សាកសព ព្រះគម្ពីរគួរអាន

អ្នកជម្ងឺ ជនពិការ

ច្បាប់ទម្លាប់នៅលើផែនដី សាសនាដទៃ

សេចក្តីគោរពមានច្រើនប្រភេទ ច្រើនបែបគឺ៖ សេចក្តីគោរពចំពោះឪពុកម្តាយ ចំពោះមនុស្សចាស់ ចំពោះអ្នកជិតខាង ។ល។ តែសេចក្តីគោរពចម្បងគឺសេចក្តីគោរពចំពោះអល់ឡោះហ៍ سُبْحَانَهُ وَ تَعَالَى ព្រះអ្នកបង្កើតយើង ។

## សេចក្តីគោរព (ការតព្វកិច្ច) ចំពោះអល់ឡោះហ៍ﷻ

អល់ឡោះហ៍ﷻជាព្រះអ្នកបង្កើតយើង ជាអ្នកទ្រទ្រង់ (ព្រះអង្គﷻរក្សាយើងឲ្យមានជីវិត) ។ ព្រះអង្គﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ ហ៊ូដ អាយ៉ាស្វ 6 (11:6) ថា៖

۞وَمَا مِن دَآبَّةٍ فِي ٱلۡأَرۡضِ إِلَّا عَلَى ٱللَّهِ رِزۡقُهَا وَيَعۡلَمُ مُسۡتَقَرَّهَا وَمُسۡتَوۡدَعَهَاۚ كُلّٞ فِي كِتَٰبٖ مُّبِينٖ ٦

*6. នៅលើផែនដី ពុំមានសត្វណាមួយឡើយដែលការទ្រទ្រង់ជីវិត (អាហារនិងការចិញ្ចឹម) របស់វាមិនមែនជាភារកិច្ចរបស់អល់ឡោះហ៍ ។ ព្រះទ្រង់ញាណលំនៅនិងជម្រករបស់វា ។ សព្វគ្រប់មានចារឹកនៅក្នុងព្រះគម្ពីរបំភ្លឺ ។*

នៅក្នុងអាយ៉ាស្វនេះ យើងអាចនិយាយបានថាព្រះម្ចាស់ﷻយើងស័ក្តិសមជាទីគោរពខ្ពង់ខ្ពស់បំផុតព្រោះព្រះអង្គﷻប្រទានកម្លាំងពលំឲ្យយើង ដើម្បីមានជីវិតរស់នៅ ឲ្យយើងអាចដកដង្ហើមចេញចូលបាន ឲ្យបេះដូងយើងអាចដំណើរការបាន ឲ្យយើងចេះគិត... និងឲ្យយើងរស់រានមានជីវិតបាន ។

យើងត្រូវគោរពអល់ឡោះហ្ម៍عزّ وجلّដូចម្តេច ?

យើងត្រូវគោរពអល់ឡោះហ្ម៍عزّ وجلّ ដោយអនុវត្តិតាមទង្វើដែលជាកាតព្វកិច្ចចារនៅក្នុងព្រះគម្ពីរគួរអានដើម្បីផលប្រយោជន៍យើង និងដើម្បីអរព្រះគុណព្រះអង្គعزّ وجلّ ដែលបានព្រះរាជទានសព្វសារពើឲ្យយើង ។

## សេចក្តីគោរព (ការតព្វកិច្ច) ចំពោះអាស្ហ៍លុល-បៃត៏عليهم السلام

អាស្ហ៍លុល-បៃត៏عليهم السلامគឺព្រះសន្តបុគ្គល ដែលអល់ឡោះហ្ម៍عزّ وجلّបានចាត់បញ្ជូនមកគឺបុគ្គលបរិសុទ្ធនិងអរិុទ្ធគ្មានបាប ។ ព្រះអង្គទាំងអស់នេះعليهم السلامជាអ្នកអភិរក្សសាសនាអ៊ីស្លាមនិងជាមគ្គទេសក៍ដឹកនាំផ្លូវ ចាត់បញ្ជូនមកដោយអល់ឡោះហ្ម៍عزّ وجلّ សម្រាប់មនុស្សជាតិ ដើម្បីធ្វើឲ្យយើងនៅលើមាគ៌ាត្រូវ ។ ត្រូវគោរពព្រះសន្តបុគ្គលទាំងនេះព្រោះព្រះអង្គعليهم السلامជាអំណោយដែលមកពីអល់ឡោះហ្ម៍عزّ وجلّ និងព្រោះតែព្រះអង្គعليهم السلامបានលះបង់និងពុះពារគ្រប់ឧបសគ្គដែរ ដើម្បីនឹងឲ្យសច្ចធម៌បានមកដល់យើង ។ យើងត្រូវគោរពព្រះសាស្តាចុងក្រោយរបស់យើង ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ៍صلى الله عليه وآله وسلم ដែលជាចុងបញ្ចប់នៃបេសកកម្មសាស្តា ។

យើងត្រូវគោរពព្រះសន្តអ៊ីម៉ាំយើងعليهم السلامដែរ ព្រោះព្រះអង្គعليهم السلامបកស្រាយអធិប្បាយលំអិតពាក្យពេជន៍ភាគច្រើនរបស់ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ៍صلى الله عليه وآله وسلم ។ យើងត្រូវគោរពព្រះអង្គទាំងអស់នេះعليهم السلام ជាពិសេសអ៊ីម៉ាំទី ១២ ព្រោះព្រះអង្គصلوات الله عليه والسلامជាអ៊ីម៉ាំរបស់សម័យកាលយើង ។

អំណឹះតទៅ ពេលយើងឲ្យសាឡាមឬស៊ីរ៉ាស្ហ៍ព្រះអង្គعليهم السلام យើងគប្បីយកចិត្តទុកដាក់អំពីពាក្យពេជន៍ដែលយើងថា និងយកចិត្តទុកដាក់អំពីបុគ្គលដែលយើងឧទ្ទិសពាក្យពេជន៍នោះ ។

**មេរៀនទី ៤**

# សេចក្តីគោរព - ភាគ ២

## សេចក្តីគោរពចំពោះម៉ាយ៉ាលិស (مجالس) ចំពោះព្រះគម្ពីរគួរអាននិងចំពោះអាស្សាន

ព្រះគម្ពីរគួរអានមាននូវសិក្ខាបទរបស់ព្រះគម្ពីរទាំងបីឯទៀត គឺព្រះគម្ពីរតៅរ៉ត្ត ព្រះគម្ពីរស្សាប៊ូរ និងព្រះគម្ពីរអ៊ិនយ៉ីល ។ អល់ឡោះហ៍ سُبْحَانَهُ وَ تَعَالَى មានព្រះបន្ទូលនៅក្នុងស៊ូរ៉ោះត៍ អាល់-អាន់អ៊ាំ អាយ៉ាស់ 92 (6:92) អំពីព្រះគម្ពីរគួរអានថា៖

وَهَٰذَا كِتَٰبٌ أَنزَلْنَٰهُ مُبَارَكٌ مُّصَدِّقُ ٱلَّذِى بَيْنَ يَدَيْهِ وَلِتُنذِرَ أُمَّ ٱلْقُرَىٰ وَمَنْ حَوْلَهَا ۚ وَٱلَّذِينَ يُؤْمِنُونَ بِٱلْءَاخِرَةِ يُؤْمِنُونَ بِهِۦ ۖ وَهُمْ عَلَىٰ صَلَاتِهِمْ يُحَافِظُونَ ﴿٩٢﴾

*92. នេះគឺគម្ពីរដែលយើងបានបើកឲ្យដឹង (គឺគួរអាន) [ជាគម្ពីរដែល]ប្រកបដោយពរជ័យសិរីសួស្តី អះអាងបន្ថែមពីលើអ្វីដែលមានពីមុននោះមកហើយ ដើម្បីនឹងឲ្យអ្នកដាស់តឿនមាតាបណ្តាស្រុក (គឺម៉ាក់កាស់) និងមនុស្សដែលនៅជុំវិញនោះ (គឺលើផែនដី) ។ អ្នកទាំងឡាយណាដែលជឿលោកមុខ ជនទាំងនោះជឿវត្ថុនេះដែរ (គឺគួរអាន) យកចិត្តទុកដាក់នឹងនមស្ការ[បូជាអល់ឡោះហ៍] ។*

យើងត្រូវរក្សាសេចក្តីស្ងៀមស្ងាត់ក្នុងពេលសូត្រព្រះគម្ពីរគួរអាន ត្រូវមានទឹកវូឌុអ៊ុមុនប៉ះឬសូត្រព្រះគម្ពីរគួរអានជានិច្ច យើងត្រូវទុកឬដាក់ព្រះគម្ពីរគួរអាននៅពីលើសៀវភៅឬតម្រាងទៀតជានិច្ច ។

យើងត្រូវគោរពអាស្សាន (أَذَان) ដូចព្រះគម្ពីរគួរអានដែរ ។ គេបានរាយការណ៍ថានិយាយក្នុងពេលគេសូត្រអាស្សានឬក្នុងពេលគេសូត្រគួរអាន ស្មើនឹងខាតរង្វាន់ (គឺមិនបានពរជ័យ) អស់ចិតសិបឆ្នាំ ។

គោរពម៉ាយ៉ាលិសបានសេចក្តីថា យកចិត្តទុកដាក់ពេលលោកអ៊ុលិម (លោកអ្នកប្រាជ្ញអ៊ីស្លាម) សម្តែងធម៌ឬធ្វើសុន្ទរកថាសាសនា ។ និយាយក្នុងពេលគេបើកអង្គប្រជុំម៉ាយ៉ាលិសជាទម្លាប់អាក្រក់ ។ បើគេនិយាយជាភាសាផ្សេងនៅក្នុងម៉ាយ៉ាលិស យើងត្រូវសាកស្តាប់និងសាកយល់ បើនៅតែមិនយល់ទេ អ្នកគប្បីដាក់

សៀវភៅអានផ្នែកសាសនាមកពីផ្ទះ ហើយអានសៀវភៅនេះក្នុងពេលគេធ្វើសុន្នរកថានោះ ។ ពេលអ្នកត្រឡប់មកផ្ទះវិញ ចូរសួរឪពុកម្តាយឲ្យពន្យល់ប្រាប់អ្នកអ្វីដែលគេបាននិយាយនៅក្នុងម៉ាយ៉ាលិស ។

## សេចក្តីគោរព (និងកាតព្វកិច្ច) ចំពោះចាស់ទុំនិងអ្នកជិតខាង

គោរពចាស់ទុំជាប្រការសំខាន់ណាស់ ។ គេថាគោរពចាស់ទុំជាទង្វើល្អប្រពៃ ។ វិធីមួយសម្រាប់គោរពចាស់ទុំគឺគំនាប់លោកពេលអ្នកជួបលោក ។ ចូរកុំចាំឲ្យលោកគំនាប់យើងមុន តែចូរអ្នកចាប់ផ្តើមគំនាប់លោកមុនដោយថាៈ

"اَلسَّلَامُ عَلَيْكُمْ وَ رَحْمَةُ اللّٰهِ وَ بَرَكَاتُهُ - អាស់សាឡាមូ អុាឡៃគុម វ៉ា រ៉ោះហ្មាទុលឡឡហ្ហ៊ី វ៉ា បារ៉កាទុះហ្វ"

យើងត្រូវព្យាយាមគំនាប់គេមុន ពីព្រោះព្រះសាស្តាមូហ៊ាំម៉ាដ្ ﷺមានព្រះវចនៈថាអ្នកឲ្យសាឡាមគេមុនបានរង្វាន់ ៩០% អ្នកឆ្លើយតបសាឡាមគេបានរង្វាន់ ១០% ។

ព្រះសាស្តាមូហ៊ាំម៉ាដ្ ﷺបានបង្ហាត់បង្រៀនយើងថា យើងត្រូវគោរពរៀមច្បង ចាស់ទុំយើងជានិច្ច ព្រោះលោកមានពេលនិងមានឱកាសធ្វើអំពើល្អច្រើនជាងយើង ។ ព្រះអង្គ ﷺបានឲ្យយើងគោរពបុគ្គលក្មេងជាងយើងដែរ ព្រោះពួកគេមានពេលធ្វើអំពើអាក្រក់តិចជាងយើង ។ យើងត្រូវគោរពបុគ្គលអាយុតំណាលយើងដែរ ព្រោះយើងមិនដឹងថាពួកគេបានប្រព្រឹត្តបាបអ្វីខ្លះទេ តែយើងស្គាល់បាបខ្លួនឯង ។

វិធីគោរពចាស់ទុំមួយទៀតគឺស្តាប់បង្គាប់លោក ។

អល់ឡោះហ្វ៍ سُبْحَانَهُ وَ تَعَالَى មានព្រះបន្ទូលថាលំអរបស់សហគមន៍គឺចាស់ទុំ ។ លោកជាប្រភពនៃប្រការល្អប្រសើរច្រើនណាស់ បើយុវជនដឹងថាអល់ឡោះហ្វ៍ عزّ وجلّ ស្រឡាញ់អស់លោកចាស់ទុំប៉ុណ្ណោះ ពួកគេប្រាកដជាមិនបោះបង់ចោលអស់លោកជាដាច់ខាត ទោះបីមួយភ្លែតក៏ដោយ ។

សេចក្តីគោរពចំពោះអ្នកជិតខាងមិនបានសេចក្តីថា គោរពតែអ្នករស់នៅក្បែរខ្លួន របងមួយនោះទេ តែគោរពបណ្តាអ្នករស់នៅជុំវិញយើងដែលអាចរស់នៅក្បែរយើងចម្ងាយ ៤០ ផ្ទះ ។ យើងត្រូវគិតដល់អ្នកជិតខាងយើង កុំប្រព្រឹត្តប្រការណាដែលនាំឲ្យគេរំខានឬបៀតបៀនគេ ។ យើងត្រូវជួយអ្នកជិតខាងយើងដែរគ្រប់

មធ្យោបាយ ពោលគឺ ដោយលះបង់ពេលវេលាខ្លះ បើចាំបាច់ ត្រូវជួយដោយថវិកា ។

ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم គួរសមចំពោះអ្នកជិតខាងណាស់ ព្រះអង្គ صلى الله عليه وآله وسلم ធ្វើច្រើនប្រការសម្រាប់អ្នកជិតខាងព្រះអង្គ صلى الله عليه وآله وسلم ដល់ថ្នាក់ពួកមុស្លីមសម័យនោះគិតថា តើវ៉ាយ៉ិបត្រូវដាក់អ្នកជិតខាងនៅក្នុងមរតកសាសន៍ដែរឬទេ (គឺឲ្យមរតកទៅអ្នកជិតខាងមួយចំណែកដែរ) ។

## សេចក្តីគោរព (និងកាតព្វកិច្ច) ចំពោះបូជនីយស្ថាន (ពោលគឺ ព្រះបរមកោដ្ឋរបស់ម៉ាក់ស៊្លូមីន)

សេចក្តីគោរពចំពោះបូជនីយស្ថាន ពោលគឺ ព្រះបរមកោដ្ឋរបស់ម៉ាក់ស៊្លូមីន (المعصومين) ជាទីកន្លែងល្អបំផុតសម្រាប់សូមឌូអាអ៊ុំដែលមានប្រសិទ្ធិភាព (ឌូអាអ៊ុំដែលអល់ឡោះហ្ទ៍ عزوجل ទទួល) ។ មូលហេតុគឺ បើយើងទៅស៊ីរ៉ាស់កោដ្ឋអ៊ីម៉ាំអាលី صلوات الله عليه والسلام ជាឧទាហរណ៍ យើងនឹកដល់ព្រះអង្គ صلوات الله عليه والسلام និងការលះបង់របស់ព្រះអង្គ صلوات الله عليه والسلام ដើម្បីអល់ឡោះហ្ទ៍ عزوجل ។ អាស្រ័យហេតុនេះ យើងនឹងនឹកដល់អល់ឡោះហ្ទ៍ عزوجل កាន់តែច្រើនឡើង ដូច្នេះយើងនឹងសូមឌូអាអ៊ុំដោយស្មោះអស់ពីចិត្តខ្លាំងឡើង អាស្រ័យហេតុនេះ ឌូអាអ៊ុំយើងនឹងមានប្រសិទ្ធិភាពខ្លាំង (គឺមានសង្ឃឹមច្រើនថាគេនឹងទទួលយកឌូអាអ៊ុំយើង) ។

ឧទាហរណ៍ សិស្សម៉ាដ្រ៉សាស់ (សិស្សសាលា អាស្ហ៊ុលុល-បៃត៍ عليهم السلام) ទៅស៊ីរ៉ាស់ (ពោលគឺ ស៊ីរ៉ាស់ព្រះបរមកោដ្ឋរបស់ម៉ាក់ស៊្លូមីន) ពីរអាទិត្យ ។ មូលហេតុធំមួយគត់ដែលពួកគេទៅស៊ីរ៉ាស់នោះគឺពួកគេដឹងច្បាស់ថា ពួកគេទៅស៊ីរ៉ាស់កន្លែងដែលសេចក្តីប៉ងប្រាថ្នាហ្វាឡាល់ទាំងអស់របស់ពួកគេ នឹងបានសម្រេចដូចបំណងព្រោះអល់ឡោះហ្ទ៍ عزوجل ព្រះដ៏មានព្រះមហិទ្ធិឫទ្ធិ នឹងទទួលយកសេចក្តីប៉ងប្រាថ្នារបស់ពួកគេ ។ កាតព្វកិច្ចរបស់យើងចំពោះបូជនីយស្ថានគឺ៖

-ទៅស៊ីរ៉ាស់ឲ្យបានទៀងទាត់ បើអាចធ្វើបាន ។

-ការពារបូជនីយស្ថានទាំងនោះ បើចាំបាច់ ។

## សេចក្តីគោរព (និងកាតព្វកិច្ច) ចំពោះអ្នកស្លាប់និងសាកសព

សេចក្ដីគោរពចំពោះសាកសពជាប្រការចាំបាច់សម្រាប់មុស្លីមគ្រប់រូប ទោះបីអ្នកស្លាប់នោះជាមុស្លីមក៏ដោយ មិនមែនមុស្លីមក៏ដោយ ។ បើអ្នកស្លាប់ជាមុស្លីមត្រូវបំពេញពិធីខ្លះមុនបញ្ចុះសាកសព ដូចជា ផ្ងូតទឹកម៉ាយិត គ្រងសំពត់កាហ្វាន់ (الكفن) ស្ម៉ូឡាត់ម៉ាយិត ជាដើម ។ យើងត្រូវប្រព្រឹត្តចំពោះសាកសពនិងប៉ះពាល់សាកសពដោយប្រុងប្រយ័ត (ថ្នមដៃ) ព្រោះវិញ្ញាណរបស់អ្នកស្លាប់អាចនៅតែដឹងការឈឺចាប់នៅឡើយ ។ ម៉ាយិតមានសិទ្ធិរបស់វាគឺ៖ គេមិនត្រូវនិយាយអាក្រក់អំពីម៉ាយិតទេ ព្រោះវាជាការនិយាយដើមគេ ។ បើយើងឃើញសាកសពមានស្នាមអ្វីក៏ដោយ យើងមិនត្រូវនិយាយប្រាប់គេទេ ព្រោះវាជាការខ្វះសេចក្ដីគោរពចំពោះអ្នកស្លាប់ ។

យើងត្រូវទៅស៊ីរ៉ាស់ផ្ទះអ្នកស្លាប់ឲ្យបានញឹកញយ ត្រូវឲ្យសាឡាមទៅអ្នកស្លាប់នៅទីនោះ ។ យើងត្រូវសូត្រគួរអាន ឌូអ៊ាអ៍ បួងសួងឧទ្ទិសទៅអ្នកស្លាប់ និងធ្វើទង្វើល្អក្នុងនាមអ្នកស្លាប់ ។

**មេរៀនទី ៥**

# សេចក្តីគោរព - ភាគ ៣

## សេចក្តីគោរព (និងកាតព្វកិច្ច) ចំពោះច្បាប់ស្មូរីអ៊ាស្ម៉ុនិងចំពោះសាសនាឯទៀត

សេចក្តីគោរពចំពោះសាសនាឯទៀត ជាករណីយកិច្ចមួយដែលមុស្លីមត្រូវអនុវត្ត ។ យើងមិនត្រូវបង្អាប់បន្ថោកសាសនាដទៃទេ តែផ្ទុយពីនោះយើងត្រូវអធិប្បាយបំភ្លឺឲ្យគេយល់សាសនាអ៊ីស្លាមដើម្បីនឹងឲ្យគេទៅជាមុស្លីមដែរ ។ យើងមិនត្រូវប្រមាថមើលងាយសាសនាដទៃជាដាច់ខាត ។ សាសនាធំៗទាំងអស់មកពីអល់ឡោះហ៍ سُبْحَانَهُ وَ تَعَالَى ព្រោះមានតែព្រះមួយគត់ ។ តែសាសនាទាំងនេះត្រូវបំភ្លៃដោយបុគ្គលក្នុងសម័យនានាតរៀងមក ដើម្បីឲ្យសមទៅតាមចិត្តខ្លួនឯង ។ យើងត្រូវមានសមត្ថភាពមើលឃើញសច្ចៈធម៌ (ការពិត) នៅក្នុងសាសនាភាគច្រើន និងមានសមត្ថភាពពន្យល់ប្រាប់បណ្តាអ្នកមានសទ្ធាពិតប្រាកដ ឲ្យយល់សាសនាអ៊ីស្លាម ។

យើងមិនត្រូវប្រមាថសាសនាឯទៀតជាដាច់ខាត ព្រោះគេអាចប្រមាថយើងវិញបានដែរ ។ ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-អាន់អ៊ុាំ អាយ៉ាស៍ 108 (6:108) ចែងថា៖

وَلَا تَسُبُّوا۟ ٱلَّذِينَ يَدْعُونَ مِن دُونِ ٱللَّهِ فَيَسُبُّوا۟ ٱللَّهَ عَدْوًۢا بِغَيْرِ عِلْمٍۗ كَذَٰلِكَ زَيَّنَّا لِكُلِّ أُمَّةٍ عَمَلَهُمْ ثُمَّ إِلَىٰ رَبِّهِم مَّرْجِعُهُمْ فَيُنَبِّئُهُم بِمَا كَانُوا۟ يَعْمَلُونَ ﴿١٠٨﴾

*108. [ម្នាលអ្នកមានសទ្ធាអើយ] ចូរពួកអ្នកកុំប្រមាថមើលងាយបណ្តាអ្នកដែលបួងសួង[រូបបដិមា...]ផ្សេងពីអល់ឡោះហ៍ [ហើយក៏កុំប្រមាថមើលងាយបណ្តារូបបដិមារបស់ពួកគេរឡើយដែរ] ក្រែងលោពួកគេនឹងប្រមាថមើលងាយអល់ឡោះហ៍ ដោយសារកំហឹង ដោយប្រាសចាកការចេះដឹង ។ យើងបានលំអទង្វើរបស់សហាគមន៍នីមួយៗឲ្យពួកគេដូច្នេះឯង ។ បន្ទាប់ពីនោះពួកគេនឹងវិលត្រឡប់ទៅឯព្រះម្ចាស់ពួកគេវិញ [ពួកគេនឹងត្រូវជំនុំជម្រះ] ។ ព្រះអង្គនឹងឲ្យពួកគេដឹងអំពីអំពើ*

*ដែលពួកគេបានប្រព្រឹត្ត (គឺកាលពីនៅរស់)* ។

ច្បាប់ស្ហារីអាុស្ស៊ុអ៊ីស្លាមជាសំណុំច្បាប់និងបទបញ្ញាផ្សេងៗ សម្រាប់ដឹកនាំរបៀបរស់នៅអ៊ីស្លាមរបស់បុគ្គល ។ កាតព្វកិច្ចមួយរបស់មុស្លីមគឺគោរពនិងអនុវត្តច្បាប់ទាំងនេះនិងព្យាយាមយល់ដឹងច្បាប់ទាំងនេះអស់ពីសមត្ថភាព ។

បើយើងមិនយល់ច្បាប់ណាមួយ យើងត្រូវព្យាយាមរិះគិតនិងព្យាយាមយល់អត្ថន័យនិងខ្លឹមសាររបស់ច្បាប់នោះ មិនត្រូវចំអកឬប្រមាថច្បាប់នោះទេ ។

## សេចក្តីគោរព (និងកាតព្វកិច្ច) ចំពោះជនពិការនិងជនកាយវិកល

ជនពិការគឺជនដែលខ្វះលក្ខណៈនីមួយក្នុងខ្លួនប្រាណ បណ្តាលឲ្យជននោះមិនអាចធ្វើប្រការខ្លះបានជាធម្មតាដូចអ្នកដទៃដែរក្នុងជីវិតរស់នៅ ។ សេចក្តីគោរពចំពោះជនពិការមានន័យថាត្រូវប្រព្រឹត្តចំពោះអ្នកនោះដូចមនុស្សធម្មតា ត្រូវសម្តែងសេចក្តីស្រឡាញ់រាប់អានចំពោះអ្នកនោះ ត្រូវជួយអ្នកនោះមុនអ្នកនោះសូមឲ្យយើងជួយ ។

កាតព្វកិច្ចចំពោះបុគ្គលទាំងនេះគឺមើលខុសត្រូវលើពួកគាត់ ពោលគឺ ផ្តល់ឲ្យគាត់នូវអ្វីដែលគាត់ត្រូវការ រស់នៅជាមួយគាត់តាមធម្មតា ព្រោះ ក្រៅពីអាការក្រៅគាត់មិនខុសពីយើងទេ ។ យើងមិនត្រូវសម្តែងការឈឺចាប់ដាក់គាត់ទេ ព្រោះគាត់មិនចង់បានការឈឺចាប់ពីយើងទេ ។ ពួកគាត់ជាមនុស្សដូចយើងដែរ អ្វីដែលពួកគាត់ត្រូវការគឺការយល់ចិត្ត ការចេះគិតដល់ពួកគាត់ ។ បើយើងសម្តែងការឈឺចាប់ដាក់ពួកគាត់ ពួកគាត់នឹងគិតថាអន់ខ្សោយជាងយើង ។ យើងត្រូវចាត់ទុកពួកគាត់ជាបុគ្គលស្មើយើងនិងដូចយើងដែរ ។

## សេចក្តីគោរព (និងកាតព្វកិច្ច) ចំពោះលោកគ្រូអ្នកគ្រូ

សេចក្តីគោរពចំពោះលោកគ្រូអ្នកគ្រូ ជាប្រការសំខាន់ស្មើសេចក្តីគោរពចំពោះឪពុកម្តាយដែរ ។ បុគ្គលដែលបង្ហាត់បង្រៀនយើងនោះ ឲ្យមកយើងនូវវត្ថុមួយដែលមានតម្លៃជាងទ្រព្យឯទៀត ព្រោះចំណេះជាទ្រព្យប្រសើរបំផុត ។ យើងមិនត្រូវប្រមាថលោកគ្រូអ្នកគ្រូជាដាច់ខាត យើងគប្បីនិយាយតិចនៅចំពោះមុខលោកគ្រូអ្នកគ្រូ ។

ព្រះសាស្ដានិងព្រះសន្ដអ៊ីម៉ាំទាំងអស់عليهم السلام ជាគ្រូនិងជាមគ្គុទេសក៏ដឹកនាំ ។ ឪពុកម្ដាយក៏ជាគ្រូដែរ ព្រោះលោកចំណាយពេលច្រើនដើម្បីចិញ្ចឹមនិងអប់រំយើង ។ យើងត្រូវស្ដាប់បង្គាប់លោកគ្រូអ្នកគ្រូដូចយើងស្ដាប់បង្គាប់ឪពុកម្ដាយដែរ ។

គេអាចសម្ដែងសេចក្ដីគោរពបាន ដោយឈរត្រង់ខ្លួននៅចំពោះមុខលោកគ្រូអ្នកគ្រូ និងដោយមិននិយាយពេលលោកកំពុងនិយាយ ។ គេត្រូវខិតខំទាញយកផលប្រយោជន៍ពីការបង្ហាត់បង្រៀនរបស់លោកគ្រូអ្នកគ្រូ ដោយសាកសួរលោក ។ គេអាចធ្វើបែបនេះបានចំពោះលោកគ្រូអ្នកគ្រូទាំងអស់ ទោះបីនៅម៉ាដ្រ៉សាស្ (សាលារៀនអ៊ីស្លាម) នៅឯសាលារៀនរដ្ឋឬនៅឯទីកន្លែងផ្សេងៗក៏ដោយ ។

## សេចក្ដីគោរព (និងកាតព្វកិច្ច) ចំពោះច្បាប់របស់ដែនដី

មុស្លីមត្រូវគោរពច្បាប់របស់ដែនដីដែលខ្លួនរស់នៅ ទោះបីដែនដីនោះជាស្រុកមុស្លីមក្ដី មិនមែនស្រុកមុស្លីមក្ដី ។ បើយើងមិនអាចគោរពច្បាប់របស់ដែនដីនោះបានទេ មិនមានមធ្យោបាយផ្លាស់ប្ដូរច្បាប់នោះទេ ឧទាហរណ៍ អាស្រ័យសភាយើងត្រូវភៀសខ្លួនទៅរស់នៅឯទីកន្លែងផ្សេង ។

មិនបានសេចក្ដីថាយើងត្រូវបំភ្លេចចោលច្បាប់អ៊ីស្លាមនោះទេ ព្រោះច្បាប់នេះមិនជាប់ពាក់ព័ន្ធតែនឹងដែនដីឬព្រំប្រទល់នីមួយដាច់មុខនោះទេ តែវាជាច្បាប់ដែលត្រូវដាក់មកលើមុស្លីមគ្រប់រូបក្នុងពិភពលោកទាំងមូល ។

**មេរៀនទី ៦**

# របៀបស្លៀកពាក់

គេស្លៀកពាក់ដោយមានមូលហេតុផ្សេងៗគឺ៖

១. ដើម្បីបិទបាំងខ្លួន ។

២. ដើម្បីកុំឲ្យរងា ។

៣. ដើម្បីស្អាតនិងឆើតឆាយ ។

មូលហេតុទាំងនេះជាមូលហេតុត្រឹមត្រូវ តែអ្នកខ្លះស្លៀកពាក់ដើម្បីឲ្យគេមើលមកខ្លួន ក្នុងបំណងឲ្យគេសរសើរខ្លួន ។ ប្រការនេះមិនល្អទេ ព្រោះយើងប្រើសំលៀកបំពាក់ដើម្បីនឹងឲ្យមនុស្សសម្លឹងមើលខ្លួនប្រាណយើង ។

*"បើអ្នកណាមួយស្លៀកពាក់ស្អាត អួតខ្លួនដោយសំលៀកបំពាក់ដាក់អ្នកដទៃ ភ្លើងនរកនឹងចាប់ខ្លួនអ្នកនោះ អ្នកនោះនឹងអណ្តែតទៅតាមអណ្តាតភ្លើងនោះរហូតដល់ថ្ងៃជំនុំជម្រះ ។"* បានសេចក្តីថាអ្នកនោះនឹងត្រូវផ្តន្ទាទោសមួយប៉ែកក្នុងលោកនេះ (ពោលគឺ ប៉ែកនរកក្នុងលោកនេះ) ។ ការផ្តន្ទាទោសអាចជាការរស់នៅដោយពុំមានមិត្រភក្តិ ឬពុំមានសុភមង្គល មិនចេះស្កប់ស្កល់ ។

ខ្លួនប្រាណយើងមានតម្លៃនិងជាឯកជន ។ អល់ឡោះហ៍ عز وجل ផ្តល់វាឲ្យយើងដើម្បីនឹងឲ្យយើងមើលថែរក្សាវា ។ យើងមិនត្រូវប្រើប្រាស់ខ្លួនប្រាណយើងខុសបែបបទទេ មិនត្រូវប្រើខ្លួនប្រាណយើងដើម្បីសម្តែងគេទេ ។ វត្ថុណាដែលមានតម្លៃនិងសំខាន់ យើងត្រូវការពារវាឆ្ងាយពីភ្នែកអ្នកដទៃ ដើម្បីនឹងកុំឲ្យអ្នកដទៃប្រើវា ធ្វើឲ្យវាខូចខាត ។ តែបើវត្ថុណាមិនមានតម្លៃទេ គេទុកវត្ថុនោះចោលឲ្យគេមើលនិងប្រើវា គេមិនបារម្ភអំពីវត្ថុនោះទេ ។ អ្វីទៅដែលមានតម្លៃជាងខ្លួនប្រាណយើងនោះ ? ដើម្បីរក្សាសេចក្តីគោរពចំពោះខ្លួនប្រាណយើង យើងត្រូវស្លៀកពាក់ដើម្បីនឹងកុំឲ្យគេឃើញខ្លួនប្រាណយើងលើសពីចាំបាច់ (គឺឲ្យនៅសល់តែកន្លែងដែលត្រូវឲ្យគេមើលឃើញ) ។

ពេលយើងស្លៀកពាក់ យើងត្រូវប្រយ័តកុំឲ្យសំលៀកបំពាក់យើងចង្អៀត ដើម្បីនឹងកុំឲ្យគេមើលឃើញរាងរបស់ខ្លួនប្រាណយើង ។ ម្យ៉ាងទៀតយើងត្រូវប្រយ័ត កុំស្លៀកពាក់សំលៀកបំពាក់ប្រភេទនីមួយនៅកន្លែងនីមួយ ។

យើងមិនត្រូវស្លៀកខោឃីន (ខោកូបូយ) ទេបើគេអញ្ជើញយើងទៅជួបស្តេចដូច្នេះ ហេតុអ្វីយើងស្លៀកខោឃីននៅឯម៉ាស់យ៊ីដ្ កន្លែងដែលយើងនៅក្បែរអល់ឡោះហ៍ﷻ ?

យើងអាចស្លៀកខោឃីន (ខោកូបូយ) នៅផ្ទះឬពេលយើងចេញទៅលេងខាងក្រៅផ្ទះបាន តែយើងគប្បីចៀសវាងស្លៀពាក់បែបនេះនៅឯបូជនីយស្ថានដូចជាម៉ាស់យ៊ីដ្ជាដើម ។ នេះពីព្រោះសំលៀកបំពាក់ខ្លះប្រកបដោយសេចក្តីសមគួរ ។

ទោះបីក្នុងផ្ទះក៏ដោយ យើងត្រូវស្លៀកពាក់ត្រឹមត្រូវ ។ ដើរនៅក្នុងផ្ទះឥតពាក់អាវឬដោយស្លៀកតែខោទ្រនាប់ឬខោខ្លីជាប្រការខ្វះសីលធម៌ ។ ទង្វើបែបនេះគួរឲ្យចង់សើច តែបុគ្គលភាគច្រើនធ្វើបែបនេះ ។

បើអ្នកទុកខ្លួនប្រាណអ្នកជាវត្ថុគ្មានតម្លៃ ចូរអ្នកកុំភ្ញាក់ផ្អើរបើគេប្រព្រឹត្តមកលើខ្លួនអ្នកដូចរបស់ថោកទាប គ្មានតម្លៃដែរនោះ ។

## មេរៀនទី ៧

# ចិត្តទូលាយ

បានសេចក្តីថាបរិច្ចាគទ្រព្យឲ្យអ្នកដទៃ តែមិនមែនបរិច្ចាគឲ្យតែបន្តិចបន្តួចនោះទេ ។

ចិត្តទូលាយមានច្រើនបែប គឺៈ

១. បរិច្ចាគឲ្យជាទាន ។

២. ផ្តល់អាហារដល់ជនក្រីក្រ ។

៣. លះបង់ពេលវេលាដើម្បីជួយអ្នកដទៃ ។

ដើម្បីមានចិត្តទូលាយអ្នកមិនចាំបាច់មានប្រាក់ទេ ។ អ្នកអាចមានចិត្តទូលាយបានដោយលះបង់ពេលវេលាផ្ទាល់ខ្លួនដើម្បីជួយអ្នកដទៃ ។

ក្មេងៗនិងយុវជនគិតថាទាល់តែពេញវ័យ គ្រប់អាយុ ទើបអាចធ្វើវិភាគទានបាន ។ មិនពិតទេ ។ ពេលកូនក្មេងដាក់ទាន ធ្វើឲ្យអល់ឡោះហ៍ﷻទ្រង់សព្វព្រះហឫទ័យជាងមនុស្សចាស់ដាក់ទានរបស់ដូចគ្នា ។ នេះពីព្រោះកូនក្មេងមិនទាន់អាចរកប្រាក់ចំណូលបានដោយខ្លួនឯងនៅឡើយ ដូច្នេះវាមិនមានប្រាក់ច្រើនទេ ។ ដូច្នេះ ពេលវាបរិច្ចាគប្រាក់នោះឲ្យទៅជនក្រីក្រ វាបានលះបង់អ្វីដែលមានតម្លៃសម្រាប់វាលើសប្រាក់នោះមានតម្លៃសម្រាប់មនុស្សចាស់ទៅទៀត ។

អល់ឡោះហ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-ឡៃល៍ អាយ៉ាស់ 5-7 (92:5-7) ថាៈ

فَأَمَّا مَنْ أَعْطَىٰ وَٱتَّقَىٰ ﴿٥﴾ وَصَدَّقَ بِٱلْحُسْنَىٰ ﴿٦﴾ فَسَنُيَسِّرُهُۥ لِلْيُسْرَىٰ ﴿٧﴾

*5. ចំណែកឯបុគ្គលដែលបរិច្ចាគ[លើមាគ៌ាអល់ឡោះហ៍] ដែលខ្លាចក្រែង [អល់ឡោះហ៍] 6. ដែលព្រមជឿជាក់អ្វីដែលល្អប្រសើរបំផុត 7. យើងនឹងឲ្យអ្នកនោះស្រួលទៅកាន់សេចក្តីស្រណុក ។*

ព្រះសាស្តាមូហាំម៉ាត់ﷺមានព្រះវចនៈថា៖ "មនុស្សចិត្តទូលាយជាមិត្តរបស់អល់ឡោះហ្ OFFSETS អល់ឡោះ عزّ وجلّ ។ មនុស្សកំណាញ់ជាសត្រូវរបស់អល់ឡោះ عزّ وجلّ ។"

## មេរៀនទី ៨

# ដាក់ខ្លួន-រាបសា

មានន័យថាស្គាល់ឋានៈគ្នាទៅវិញទៅមកក្នុងសាសនាអ៊ីស្លាម ។

គេឲ្យយើងដឹងថា ក្នុងសាសនាអ៊ីស្លាមពុំមានអ្នកណាគ្រាន់បើជាងអ្នកណាទេ ។ ដូច្នេះការដាក់ខ្លួនគឺដឹងខ្លួនថាយើងមិនប្រសើរជាងអ្នកដទៃទេ ថាយើងត្រូវប្រព្រឹត្តខ្លួនបែបនេះ ។ សត្រូវធំបំផុតរបស់ការដាក់ខ្លួនគឺណាហ្វ៍ស៍ (نَفْس) យើង ។ ពេលណាយើងធ្វើប្រការល្អ ណាហ្វ៍ស៍យើងប្រាប់យើងថាយើងបានធ្វើអ្វីមួយដែលប្រសើរបំផុត វាធ្វើឲ្យយើងមានអារម្មណ៍ថាយើងជាបុគ្គលថ្កុំថ្កើង ។ នេះបានសេចក្ដីថា**យើងត្រូវការពារខ្លួនយើង**កុំឲ្យបានចិត្ត (គឺមានមោទនភាពហួសពេក) ។

អ៊ីមុាំទី ៤ របស់យើងﷺមានវចនៈនៅក្នុងសាត្រា អាស្វ៍-ស្វ៍ហ៊ីហ្វាស្ទុ៎ អាល់-កាមីឡាស្ទុ៎ អាស់-សាច់យ៉ាដ្ជីយ៉ាស្ទុ៎ (اَلصَّحِيفَةُ الْكَامِلَةُ السَّجَّادِيَّةُ) ថា៖ "ព្រះម្ចាស់ﷻអើយ សូមព្រះអង្គﷻកុំលើកតម្កើងទូលព្រះបង្គំជាខ្ញុំមួយកម្រិត លើសអ្នកផងទាំងឡាយឡើយ បើព្រះអង្គﷻមិនបន្ទាបទូលព្រះបង្គំជាខ្ញុំមួយកម្រិតដែរនៅក្នុងចិត្តទូលព្រះបង្គំជាខ្ញុំទេនោះ ។ សូមព្រះអង្គﷻកុំឲ្យទូលព្រះបង្គំជាខ្ញុំបាននូវសេចក្ដីគោរពប៉ែកក្រៅឡើយ បើព្រះអង្គﷻមិនឲ្យទូលព្រះបង្គំជាខ្ញុំបាននូវសេចក្ដីអាម៉ាស់នៅក្នុងចិត្តមួយប៉ែកដែរទេនោះ ។"

ផ្ទុយពីការដាក់ខ្លួនគឺឫកធំ ។ ឫកធំឬសេចក្ដីក្រអឺតក្រទមគឺគិតថាខ្លួនឯងគ្រាន់បើជាងអ្នកដទៃ ។ នេះគឺបាបដែលអ៊ីប្លីស (ស្ដេចនរក) បានប្រព្រឹត្ត វាត្រូវបណ្ដាសាដោយសាររឿងនេះឯង ។

អ្វីទៅអ្នកដាក់ខ្លួន ? អ្នកដាក់ខ្លួនគឺបុគ្គលដែលចំណាយពេលដើររាប់គ្រាប់គាស់បឺះប៉ុ្រមែនទេ ?

មិនមែនទេ ។ គេអាចស្គាល់ភិនភាគរបស់អ្នកដាក់ខ្លួនបានអាស្រ័យពាក្យ

ពេជន៍របស់អ៊ីម៉ាំអ្នលីﷺថា៖ "ភិនភាគរបស់អ្នកដាក់ខ្លួនគឺការពេញចិត្តនឹងកន្លែងដែលគេចាត់ឲ្យខ្លួននៅក្នុងសភា ការគំនាប់ពេលជួបគេ ការលះបង់ចោលទំនាស់ និងការខ្វែងគំនិតគ្នាទោះបីខ្លួនជាអ្នកត្រូវក៏ដោយ និងការមិនទទួលយកការកោតសរសើរពីអ្នកដទៃព្រោះតែខ្លួនខ្លាចអល់ឡោះហ៏ﷻនោះ ។"

បុគ្គលដាក់ខ្លួនគឺបុគ្គលដែលមានចិត្តរម្យទម រាបសា ។ បានសេចក្តីថាបុគ្គលនោះមិនដើរប្រាប់គេថាខ្លួនសំខាន់ទេ បានសេចក្តីថាបុគ្គលនោះមិនបានចិត្តទេពេលគេកោតសរសើរខ្លួន ។

ហេតុអ្វីយើងត្រូវដាក់ខ្លួន ?

ពេលយើងដាក់ខ្លួន យើងសម្តែងឲ្យពិភពលោកឃើញថាអល់ឡោះហ៏ﷻបានបង្កើតមនុស្សទាំងអស់ស្មើគ្នា ទោះបីមនុស្សនោះមានសម្បុរខ្មៅក្តី ដាំដែងក្តី សក្តីលឿងក្តី ។

យើងបានបញ្ជាក់ឲ្យឃើញថា បុគ្គលដែលគ្រាន់បើសម្រាប់អល់ឡោះហ៏ﷻនោះ គឺបុគ្គលដែលខ្លាចអល់ឡោះហ៏ﷻ (គឺបុគ្គលខ្មាសខ្លួនឯង ព្រោះបុគ្គលនោះខ្លាចធ្វើឲ្យអល់ឡោះហ៏ﷻទាស់ចិត្ត) ។

ព្រះសាស្តាយើងﷺមានព្រះវចនៈថា៖ "ឫកធំឬសេចក្តីក្រឱងក្រអឺតជ្រាបចូលក្នុងខ្លួនយើងដូចពីងពាងខ្មៅវារនៅលើដុំថ្មខ្មៅពេលយប់ ។"

ពាក្យពេជន៍នេះបញ្ជាក់ប្រាប់យើងថា ឫកធំឬសេចក្តីក្រឱងក្រអឺតអាចឈ្នះយើងបានដោយងាយស្រួលបំផុត វាបង្ហាញប្រាប់យើងដែរនូវសារៈសំខាន់របស់ការដាក់ខ្លួន ដើម្បីនឹងឲ្យយើងការពារខ្លួនពីការបានចិត្ត ពីការកើតមានឫកធំក្រឱងក្រអឺត ។

នៅក្នុងឌូអាអ៊ុំពេលស៊ូឡាត់អាស្ហារ យើងទូលអល់ឡោះហ៏ﷻថា៖ "ព្រះម្ចាស់ﷻអឺយ កោសល្យទាំងអំបាលម៉ានដែលទូលព្រះបង្គំជាខ្ញុំមាននោះ វាសុទ្ធតែមកពីព្រះអង្គﷻមួយគត់ ។"

បើយើងចង់រក្សាអាការរាបសា ដាក់ខ្លួន យើងត្រូវនឹកឃើញឌូអាអ៊ុំនេះជានិច្ចសូត្រឌូអាអ៊ុំនេះរាល់ពេលដែលយើងធ្វើប្រការល្អនីមួយ ឬពេលយើងមានជោគជ័យ ឬពេលយើងឈ្នះបានអ្វីមួយ ។ ឌូអាអ៊ុំនេះនឹងទប់ណាហ្វ៏ស៍យើងមិនឲ្យវាធ្វើ

ឲ្យយើងបានចិត្ត និងធ្វើឲ្យវាកោតសរសើរអល់ឡោះហ្ ﷻ ។

ព្រះសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ការពិត អាការដាក់ខ្លួនលើកឋានៈបុគ្គលឡើងទៅក្បែរអល់ឡោះហ្ﷻ ។ ដូច្នេះ ចូរអស់លោករក្សាអាការដាក់ខ្លួនព្រោះអល់ឡោះហ្ﷻនឹងស្រោចព្រះធម៌មេត្តារបស់ព្រះអង្គﷻមកលើអស់លោក ។"

## មេរៀនទី ៩

# ការអើពើចំពោះជនខ្វះខាត

ជនខ្វះខាតគឺបណ្ដាអ្នកដែលពុំមានលទ្ធភាពគ្រប់គ្រាន់ដូចយើង ។ មិនមានន័យថាលទ្ធភាពខាងសំលៀកបំពាក់និងទ្រព្យសម្បត្តិតែម្យ៉ាងនោះទេ តែមានន័យដែរថាបណ្ដាអ្នកដែលមានបញ្ហាផ្នែករាងកាយឬខួរក្បាល ។

អល់ឡោះហ្ទ៍ﷻបានបង្កើតយើងមកដោយមានមូលហេតុពិសេស ។ ព្រះអង្គﷻបានបង្កើតមនុស្សខុសៗគ្នា មនុស្សខ្លះធំ មនុស្សខ្លះតូច មនុស្សខ្លះមានសម្បុរស មនុស្សខ្លះខ្មៅ ។

បើយើងមានសំណាងមានសុខភាពល្អ យើងមិនត្រូវបានចិត្តទេព្រោះខ្លួនប្រាណយើងមិនត្រូវបង្កើតមកដោយខ្លួនយើងទេ ។ ខ្លួនប្រាណយើងត្រូវបង្កើតមកដោយអល់ឡោះហ្ទ៍ﷻ ដូច្នេះយើងត្រូវអរព្រះគុណអល់ឡោះហ្ទ៍ﷻ ។

ព្រះសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "អស់លោករាល់គ្នាកើតមកពីអាដាំعَلَيْهِ السَّلَام អាដាំعَلَيْهِ السَّلَامកើតមកពីធូលី ។"

សឲ្យឃើញថាយើងមិនត្រូវបានចិត្ត មិនត្រូវមានមោទនភាពចំពោះខ្លួនឯងទេ យើងត្រូវចងចាំថាយើងទាំងអស់គ្នាកើតមកពីធូលី ។

បើខ្លួនប្រាណយើងមិនល្អឥតខ្ចោះទេ យើងមិនត្រូវត្អូញត្អែរទេ ព្រោះអ្នកខ្លះមានបញ្ហាធំជាងយើង ។

យើងត្រូវជួយជានិច្ចបណ្ដាអ្នកដែលមិនមានសំណាងល្អដូចយើង ដោយគ្រប់មធ្យោបាយដែលអាចធ្វើបាន យើងមិនត្រូវចំអន់លេងដាក់ជនទាំងនោះជាដាច់ខាត ។

បើយើងធ្វើបែបនេះបានសេចក្ដីថាយើងអើពើ ពុំនោះទេបានសេចក្ដីថាយើងចិត្តអាក្រក់ មិនក្រែងរអែង ។

គន្លឹះនៃសេចក្ដីមេត្តាចំពោះអ្នកដទៃគឺយើងត្រូវតាំងខ្លួនជាអ្នកនោះ ត្រូវគិតមើលអំពីជីវិតរស់នៅតាមរយៈខ្លួនអ្នកនោះ ។

ពេលចុងថ្ងៃ យើងត្រូវគិតដល់ជនខ្វះខាតទាំងនេះ ត្រូវគិតជួយពួកគាត់ ។

**មេរៀនទី ១០**

# សេចក្ដីលោភលន់

ភាសាអារ៉ាប់ហៅថា ហ៊្មៀរស្វ៍ (حِرْص) ។

លោភលន់គឺចង់បានលើសពីមានស្រាប់ហើយ ឥតឈប់ ។

មនុស្សអាចលោភលន់ច្រើនវិស័យដូចជាលោភលន់ខាងបរិភោគ លោភលន់ប្រាក់ លោភលន់សំលៀកបំពាក់ ។ល ។

សេចក្ដីលោភលន់ជាទម្លាប់អាក្រក់ ពីព្រោះបានសេចក្ដីថាយើងមិនស្កប់ចិត្តនឹងអ្វីដែលយើងមានទេ ។

ក៏ប៉ុន្តែមានវិស័យមួយដែលលោភលន់ជាប្រការល្អ គឺសេចក្ដីលោភលន់ចំណេះវិជ្ជា ។

ព្រះសាស្ដាមូហ្ាំម៉ាដ់ﷺមានព្រះវចនៈថា៖ "មនុស្សពីរប្រភេទដែលលោភលន់ឥតស្កប់ស្កល់គឺ៖ មនុស្សដែលចង់បានគំនរចំណេះចេះដឹង និងមនុស្សដែលចង់បាននូវគំនរទ្រព្យ ។

យើងត្រូវចៀសវាងលោភលន់ព្រោះវាធ្វើឲ្យមនុស្សគោរពយើងតិច ។

ឧទាហរណ៍ បើគេលោភលន់បរិភោគ គេបរិភោគចំណីដៃពីរ ត្របាក់លេបតាមដែលអាចធ្វើបាន មនុស្សនឹងមើលអ្នកនោះ នឹងគិតថាអ្នកនោះមិនដែលឃើញចំណីទេកាលពីមុនមក ។ គេនឹងគិតថាអ្នកនោះជាកូនក្មេង ហើយក៏នឹងមិនគោរពអ្នកនោះទេ ។

យើងត្រូវស្កប់ស្កល់ជានិច្ចអ្វីដែលអល់ឡោះហ្ ﷻប្រទានឲ្យយើង ។ បើយើងចង់បានច្រើនលើសនេះ យើងត្រូវធ្វើការដើម្បីនឹងបាននូវអ្វីដែលយើងចង់បាននោះ បើអល់ឡោះហ្ ﷻចង់ យើងនឹងបានដូចបំណងមែន ។ ពេលយើងមានបាននូវវត្ថុខ្លះហើយ យើងត្រូវសួរខ្លួនឯងជានិច្ចថាតើយើងត្រូវការលើសពីនោះទេ បើត្រូវការទៀតវាជាសេចក្ដីលោភលន់ដែលជំរុញយើងឲ្យចង់បានច្រើនទៀត ។ វិធីប្រសើរបំផុតសម្រាប់ទប់ស្កាត់សេចក្ដីលោភលន់ គឺបែងចែកអ្វីដែលខ្លួនមានឲ្យទៅអ្នកដទៃ ។

**មេរៀនទី ១១**

# កំណាញ់

ភាសាអារ៉ាប់ហៅកំណាញ់ថា ប៊ុក្ហល៍ (بُخْل) ។

បានសេចក្តីថាឲ្យតិចណាស់អ្វីដែលខ្លួនមានទៅអ្នកដទៃដែលទ័លក្រ ។

ឧទាហរណ៍ សន្មត់ថាយើងកំពុងបរិភោគបាយ មានចំណីច្រើន ។ បើមានជនក្រីក្រណាម្នាក់មកសូមយើង យើងឲ្យគេតែបាយមួយចឹប បានសេចក្តីថាយើងកំណាញ់ ។

អល់ឡោះហ្ម៍ﷻមានព្រះបន្ទូលប្រាប់យើងថា៖ "ចូរកុំចងដៃជាប់នឹងក (ដូចដៃមនុស្សកំណាញ់) ចូរកុំហុចឲ្យលុះដៃលូតវែងហួសហេតុ ដើម្បីនឹងកុំឲ្យត្រូវស្តីបន្ទោសនិងអស់រលីងពីខ្លួន ។"

មានន័យថាយើងត្រូវមានចិត្តល្អជានិច្ច តែកុំមានចិត្តទូលាយពេកដល់ថ្នាក់គ្មានសល់អ្វីឡើយនោះ ។

បើម្តាយអ្នកឲ្យអ្នកជួយគាត់ធ្វើការ ៥ នាទី បើអ្នកវាស់ពេលធ្វើការនោះលុះដល់ ៥ នាទីត្រឹមអ្នកចោលការ ក៏ហៅថាកំណាញ់ដែរ ។

នៅក្នុងផ្ទះមិនត្រូវឲ្យមានការកំណាញ់ជាដាច់ខាត ។ ពេលប្អូនប្រុសឬប្អូនស្រីអ្នកសូមរបស់អ្វីមួយពីអ្នក អ្នកមិនត្រូវគិតដល់តម្លៃរបស់នោះទេ មិនត្រូវគិតពេលប្រើរបស់នោះទេ ។

ផ្ទុយពីកំណាញ់គឺទូលាយ ។ មានចិត្តទូលាយគឺមានសប្បុរសធម៌ ។ យើងបានរៀនអំពីសប្បុរសធម៌កន្លងមកហើយក្នុងមេរៀនទី ១១ ថ្នាក់ទី ៥ ។

អល់ឡោះហ្ម៍ﷻពន្យល់ប្រាប់យើងអំពីសប្បុរសធម៌ នៅក្នុងព្រះគម្ពីរគួរអានស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 261 (2:261) ថា៖

مَّثَلُ ٱلَّذِينَ يُنفِقُونَ أَمۡوَٰلَهُمۡ فِي سَبِيلِ ٱللَّهِ كَمَثَلِ حَبَّةٍ أَنۢبَتَتۡ سَبۡعَ سَنَابِلَ فِي كُلِّ سُنۢبُلَةٖ مِّاْئَةُ حَبَّةٖۗ وَٱللَّهُ يُضَٰعِفُ لِمَن يَشَآءُۚ وَٱللَّهُ وَٰسِعٌ عَلِيمٌ ٢٦١

*261. បណ្ដាអ្នកចាយវាយទ្រព្យរបស់ខ្លួនលើមាគ៌ាអល់ឡោះប្រៀបបាននឹងគ្រាប់ពូជដែលដុះប្រាំពីរកួរក្នុងមួយគ្រាប់ មួយកួរៗមានមួយរយគ្រាប់ ។ អល់ឡោះមានព្រះបំណងបង្កើនឲ្យអ្នកណាមួយ ស្រេចតែលើព្រះអង្គ ។ អល់ឡោះមានព្រះហឫទ័យទូលំទូលាយ ព្រះអង្គទ្រង់ញាណសព្វសារពើ ។*

## មេរៀនទី ១២

# ហ្វីតណាស់ និង ហ្វាសាដ់

(فَسَاد - فِتْنَة)

មានន័យថាដើរនិយាយពាក្យចចាមអារ៉ាមនិងនិយាយកុហកភូតភរ ដោយមានបំណង (នៀត) បង្ខូចកេរ្តិ៍ឈ្មោះអ្នកដទៃ ។

ដូចនិយាយអាក្រក់ដែរ ខុសគ្នាតែថាពាក្យចចាមអារ៉ាមជាសម្តីមិនពិត គ្មានអំណះអំណាង ។

មានពាក្យមួយទៀតសម្រាប់ហៅ ហ្វីតណាស់ ឬ ហ្វាសាដ់ គឺពាក្យថានិយាយបង្កាច់ (បង្ខូចកេរ្តិ៍ឈ្មោះគេ) ។

អ៊ីម៉ាំហ្ហាសាន់عليه والسلام صلوات اللهមានវចនៈថា៖ "ពេលអ្នកណាមួយមករកលោក និយាយអាក្រក់អំពីគេ លោកត្រូវដឹងថាអ្នកនោះកំពុងតែនិយាយអាក្រក់អំពីលោក ។ វាជាប្រការល្អដែលចាត់ទុកអ្នកនោះជាសត្រូវរបស់លោក និងកុំទុកចិត្តអ្នកនោះ ព្រោះការនិយាយកុហក ភូតភរ ការនិយាយអាក្រក់ពីគេ ការឆបោក កំហាកចិត្ត ការច្រណែន ពុតត្បុត ការបំភាន់ និងការធ្វើឲ្យមនុស្សបែកបាក់សាមគ្គីគ្នា ទាំងអស់នេះស្មើនឹងការនិយាយបង្កាច់គេ ។"

អ៊ីម៉ាំعليه والسلام صلوات اللهមានវចនៈថា៖ "បុគ្គលអាក្រក់បំផុតក្នុងចំណោមអស់លោកគឺបុគ្គលដែលនិយាយបង្កាច់គេ ដែលធ្វើឲ្យមិត្តខ្វែងគំនិតគ្នា ដោយចោទអ្នកស្លូតត្រង់ ។"

ការនិយាយបង្កាច់គេអាក្រក់ណាស់ ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "អ្នកណានិយាយបង្កាច់គេ អ្នកនោះមិនបានចូលឋានសួគ៌ទេ ។"

ការនិយាយបង្កាច់គេជាប្រការហាមឃាត់ព្រោះវាធ្វើឲ្យកេរ្តិ៍ឈ្មោះគេអសោច ។ វាជាអំពើអយុត្តិធម៌សម្រាប់បុគ្គលប្រុសស្រីណាដែលរងការនិយាយបង្កាច់ ដោយគ្មានហេតុផលព្រោះអ្នកផងនឹងគិតថា បុគ្គលប្រុសស្រីនោះបានធ្វើអ្វីដែលគាត់មិនបានធ្វើសោះ ។

ការនិយាយបង្កាច់គេធ្វើឲ្យសហគមន៍បែកបាក់ និងជួញសត្រូវដោយសាប

ព្រោះហិង្សា ។ វាជាបាបធំបំផុតមួយ ស្មើនឹងគ្តីបាត់ (غِيبَة) និងបទឧក្រិដ្ឋសង្គមឯទៀត ។

មានតែបុគ្គលកំសាកទេដែលប្រើការនិយាយបង្កាច់គេ ពីព្រោះពេលឃើញអ្នកណាមួយដែលមានគេចូលចិត្តច្រើន បុគ្គលនោះនឹងច្រណែនគេ ហើយក៏ព្យាយាមបង្ខូចកេរ្តិ៍ឈ្មោះអ្នកនោះ ។ បុគ្គលនោះមិនមានសេចក្តីក្លាហានជេរគេទល់មុខគេទេ ដូច្នេះគាត់ដើរចរច្រប់ដូចពស់អាសិរពិស សាបព្រោះនិងខ្សឹបខ្សៀវពាក្យចចាមអារ៉ាមនៅក្នុងកន្លែងងងឹត ។

# ការក្បត់ ឬ អំពើក្បត់

គឺក្បត់អ្នកណាម្នាក់ ។ ឧទាហរណ៍ ពេលយើងសន្យាជួយអ្នកណាម្នាក់ យើងចោលអ្នកនោះក្នុងពេលដែលអ្នកនោះត្រូវការជំនួយពីយើង ជាអំពើក្បត់មួយ ។

ក្នុងរជ្ជកាលអ៊ីម៉ាំហាសាន់صلوات الله عليه والسلام មូអាវីយ៉ាស៊ូបានទៅជួបមហេសីព្រះអង្គصلوات الله عليه والسلام ឈ្មោះ យ៉ាក្ទុំដាស៊ូ (جَعْدَةُ بِنْتُ الْأَشْعَثِ بْنِ قَيْسٍ الْكِنْدِيّ) បានប្រគល់ប្រាក់ឲ្យព្រះនាង ១០០០ឌៀរហ៊ាំ និងបានសន្យារៀបការកូនប្រុសខ្លួនឈ្មោះ យ៉ាស៊ីុដ្ទ ជាមួយព្រះនាង បើព្រះនាងសុខចិត្តដាក់ថ្នាំបំពុលអ៊ីម៉ាំហាសាន់صلوات الله عليه والسلام ។

យ៉ាក្ទុំដាស៊ូបានថាខ្លួនស្មោះត្រង់ចំពោះអ៊ីស្លាម ពីព្រោះព្រះនាងជាព្រះមហេសីពេញច្បាប់របស់ព្រះអង្គصلوات الله عليه والسلام ។ ព្រះនាងបានយកភេសជ្ជៈដាក់ថ្នាំបំពុលឲ្យអ៊ីម៉ាំصلوات الله عليه والسلامសោយ អ៊ីម៉ាំصلوات الله عليه والسلامក៏បានសោយភេសជ្ជៈនោះ ។

អ៊ីម៉ាំហាសាន់صلوات الله عليه والسلامបានសោយទិវង្គត ៤០ ថ្ងៃក្រោយមក ។ យ៉ាក្ទុំដាស៊ូបានទៅជួបមូអាវីយ៉ាស៊ូដើម្បីទារបំណុល ។ ព្រះនាងបានទទួលប្រាក់ តែមូអាវីយ៉ាស៊ូមិនឲ្យរៀបការជាមួយកូនប្រុសខ្លួនឈ្មោះយ៉ាស៊ីុដ្ទទេ ពីព្រោះ ដែលព្រះនាងអាចក្បត់ស្វាមីខ្លួនឯងបាននោះ ព្រះនាងក៏អាចក្បត់ស្វាមីម្នាក់ទៀតបានដែរ ។

នេះគឺគំរូក្បត់មួយ ។

មូលហេតុមួយដែលការក្បត់ឬអំពើក្បត់ជាប្រការហាមឃាត់នោះ ពីព្រោះពេលគេ

ពឹងផ្អែកលើអ្នកទាំងស្រុង ឬជឿអ្នក អ្នកមានករណីយកិច្ចទទួលខុសត្រូវលើអ្នកនោះ ។ ប្រព្រឹត្តអាក្រក់ចំពោះអ្នកនោះដោយមិនឲ្យអ្នកនោះដឹងខ្លួន បានសេចក្តីថាប្រព្រឹត្តរំលោភទៅលើអ្នកនោះ នេះជាប្រការអាក្រក់ណាស់ ។

ពាក្យស្លោកថែងថាការក្បត់ឬអំពើក្បត់ប្រៀបបាននឹងការ "ចាក់សម្លាប់គេពីក្រោយខ្នង" ។

**មេរៀនទី ១៣**

# ឈ្នានីស និង ឥច្ឆា

ឥច្ឆាគឺការចង់បានដែរនូវអ្វីដែលអ្នកដទៃមាន ។ ពាក្យមួយទៀតសម្រាប់ហៅឥច្ឆាគឺសេចក្ដីលោភ ។

នេះជាទម្លាប់អាក្រក់ ព្រោះបានសេចក្ដីថាយើងមិនស្កប់ចិត្តទេចំពោះអ្វីដែលអល់ឡោះហ្ជ័ព្រះរាជទានឲ្យយើងនោះ ។

អល់ឡោះហ្ជ័មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះតុ៍ អាន់-នីសាអ៊ុ៍ អាយ៉ាសុ៍ 32 (4:32) ថា៖

وَلَا تَتَمَنَّوْا۟ مَا فَضَّلَ ٱللَّهُ بِهِۦ بَعْضَكُمْ عَلَىٰ بَعْضٍ ۚ لِّلرِّجَالِ نَصِيبٌ مِّمَّا ٱكْتَسَبُوا۟ ۖ وَلِلنِّسَآءِ نَصِيبٌ مِّمَّا ٱكْتَسَبْنَ ۚ وَسْـَٔلُوا۟ ٱللَّهَ مِن فَضْلِهِۦٓ ۗ إِنَّ ٱللَّهَ كَانَ بِكُلِّ شَىْءٍ عَلِيمًا ﴿٣٢﴾

*32. ចូរពួកអ្នកកុំចង់បានអ្វីដែលអល់ឡោះហ្ជ័បានប្រទានឲ្យទៅបណ្ដាអ្នកខ្លះ ជាងបណ្ដាអ្នកឯទៀត ក្នុងចំណោមពួកអ្នកឡើយ ។ មនុស្សប្រុសនឹងបាននូវមួយចំណែកនៃអ្វីដែលខ្លួនរកបាន រីឯមនុស្សស្រីនឹងបាននូវមួយចំណែកនៃអ្វីដែលខ្លួនរកបាន (គឺសម្រាប់អល់ឡោះហ្ជ័មនុស្សប្រុសនិងមនុស្សស្រីស្មើគ្នា) ។ ចូរពួកអ្នកអង្វរសូមអល់ឡោះហ្ជ័នូវព្រះមេត្តាករុណារបស់ព្រះអង្គ ព្រោះអល់ឡោះហ្ជ័ទ្រង់ញាណសព្វសារពើ ។*

ទោះបីពាក្យឈ្នានីសនិងពាក្យឥច្ឆាត្រូវប្រើរួមគ្នាក៏ដោយ តែពាក្យទាំងពីរនេះខុសគ្នា ។ ឥច្ឆាមានន័យថាចង់បានឬសម្លឹងរំពៃទំនងឲ្យបានបុណ្យស័ក្តិឬទ្រព្យអ្នកដទៃមកជារបស់ខ្លួន ។ ឈ្នានីសមានន័យថាមិនចង់បានអ្វីដែលជារបស់អ្នកដទៃទេ តែថែមទាំងប៉ងប្រាថ្នាកុំឲ្យអ្នកដទៃបានរបស់នោះដែរ ។

សម័យថ្ងៃមួយមានបុរសម្នាក់មានកសិដ្ឋានមួយ ។ បុរសអ្នកជិតខាងគាត់ក៏មានកសិដ្ឋានដែរ ។ ថ្ងៃមួយ បុរសនេះបានឃើញបុរសជិតខាងគាត់កំពុងរឹតទឹក

ដោះមេគោស្អាតមួយ ។ មេគោមានទឹកដោះច្រើន ទឹកដោះវាផ្អែមឆ្ងាញ់ណាស់ ។ បុរសរូបនេះមិនពេញចិត្តទេដែលបុរសអ្នកខាងគាត់មានមេគោឲ្យផលច្រើន ។ គាត់ក្រោធណាស់ ។ ស្ថែត្ចនﷺបានមកជួបបុរសនោះ សួរគាត់ថាតើគាត់មានបញ្ហាអ្វី ។ បុរសបានចង្អុលទៅមេគោ ថា៖ "មើលចុះ មេគោរបស់អ្នកជិតខាងខ្ញុំស្អាតណាស់ ។" ស្ថែត្ចនﷺថា៖ "ប៉ុណ្ណេះឯង ? ខ្ញុំﷺនឹងឲ្យលោកមេគោដប់ដូចនេះ ។" បុរសតបថា៖ "ខ្ញុំមិនចង់បានមេគោដូចនេះទេ តែខ្ញុំចង់ឲ្យអ្នកជិតខាងខ្ញុំមិនមានមេគោនេះ ។"

រឿងនេះសឲ្យឃើញថាការឈ្នានីសអាចធ្វើឲ្យមានគ្រោះថ្នាក់ ។ វាធ្វើឲ្យមនុស្សឆ្កួត ។

អ៊ីមុាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "ការឈ្នានីសស៊ីទង្វើល្អដូចភ្លើងឆេះឈើស្ងួត ។"

យើងដឹងថាឈើស្ងួតឆេះដូចម្តេច ថាវាត្រូវភ្លើងឆាបឆេះបំផ្លាញដូចម្តេច ។ ការឈ្នានីសមានឥទ្ធិពលបែបនេះលើទង្វើយើង ។

"មនុស្សឈ្នានីសគេមិនអាចដឹកនាំសង្គមមនុស្សបានជាដាច់ខាត ។"

បានសេចក្តីថា ពេលយើងមានអ្នកដឹកនាំប្រទេសដែលមានចិត្តឈ្នានីសគេ មេដឹកនាំនោះបារម្ភតែអំពីសុភមង្គលខ្លួនឯង មិនចង់ឲ្យអ្នកដទៃល្អទេ មិនបារម្ភអំពីសុភមង្គលរបស់អ្នកដទៃទេ ។ បានសេចក្តីថាបណ្តាអ្នកនៅក្រោមបង្គាប់ខ្លួននឹងរងអំពើអាក្រក់និងរងការសង្កត់សង្កិន ដូច្នេះគេនឹងចោលមេដឹកនោះ ។

## មេរៀនទី ១៤

# បន្ទោកខ្លួនឯង

បន្ទោកខ្លួនមានន័យថាដាក់មុខ (ឱនមុខចុះ) ដោយមានអាការស្រពាប់ស្រពោននៅពីមុខអ្នកដទៃ ដូចមនុស្សសូមទានគេ ។

យើងមិនត្រូវបន្ទោកខ្លួនឯងនៅចំពោះមុខអ្នកណាមួយជាដាច់ខាត លើកលែងតែចំពោះអល់ឡោះហ៍ عز وجل មួយគត់ ព្រោះចំពោះតែព្រះអង្គ عز وجل មួយគត់ដែលយើងត្រូវទទូចសូមទាន ។ ពេលយើងបន្ទោកខ្លួនចំពោះអ្នកដទៃ យើងបាត់បង់សេចក្ដីថ្លៃថ្នូរ សឲ្យឃើញថាយើងខ្វះសេចក្ដីគោរពចំពោះខ្លួនឯង ។

ថ្ងៃមួយស្មូមម្នាក់បានទៅក្បែរអ៊ីម៉ាំហ៊ូសៃន៍ صلوات الله عليه والسلام ដើម្បីសូមប្រាក់ព្រះអង្គ صلوات الله عليه والسلام ។ អ៊ីម៉ាំ صلوات الله عليه والسلام បានឲ្យអ្នកទទួលបន្ទុកប្រាក់ប្រគល់ប្រាក់ចំនួន ១០០០ អាស់شរ៉ហ្វី (កាក់មាសសម័យនោះ) ឲ្យស្មូមនោះ ។ ស្មូមក៏បានទទួលយកប្រាក់ ។ គាត់មិនដើរចេញទេ បែរជាអង្គុយរាប់ប្រាក់យ៉ាងផ្ចិតផ្ចង់ ។ ពេលគេសួរគាត់ថាហេតុអ្វីគាត់រាប់ ស្មូមបានតបថា៖ "ម្ដេចរាប់មិនបាន ? ខ្ញុំបានលក់សេចក្ដីថ្លៃថ្នូររបស់ខ្លួនខ្ញុំហើយដោយសូមទានគេនោះ ។"

ពេលបានឮសម្ដីនេះ អ៊ីម៉ាំ صلوات الله عليه والسلام បានតបថាគាត់និយាយត្រូវ រួចហើយព្រះអង្គ صلوات الله عليه والسلام ឲ្យគេឲ្យគាត់ ១០០០ អាស់شរ៉ហ្វីទៀត ។ ពេលស្មូមបានទទួលយកប្រាក់ក្រោយពីបានរាប់រួច អ៊ីម៉ាំ صلوات الله عليه والسلام ឲ្យគាត់ ១០០០ អាស់شរ៉ហ្វីថែមទៀត ហើយព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "១០០០ អាស់شរ៉ហ្វីដំបូងសម្រាប់ការឆ្លើយតបសំណូមលោក ។ ១០០០ អាស់شរ៉ហ្វីលើកទីពីរសម្រាប់ការប្ដូរនឹងសេចក្ដីថ្លៃថ្នូររបស់លោក ។ ១០០០ អាស់شរ៉ហ្វីលើកទីបីសម្រាប់ការមកស៊ុរ៉ាស់ ដើម្បីអរគុណលោកដែលមកសូមជំនួយពីខ្ញុំ صلوات الله عليه والسلام មិនទៅសូមអ្នកផ្សេង ។"

រឿងនេះសឲ្យឃើញថា ទោះបីអ៊ីម៉ាំ صلوات الله عليه والسلام មានព្រះហឫទ័យទូលាយក៏ដោយ សូម្បីតែស្មូមសូមទានគេក៏មានកិត្តិយសនិងសេចក្ដីថ្លៃថ្នូរដែរ មិនត្រូវរងការបង្អាប់បន្ទោកពីអ្នកឲ្យជាដាច់ខាត ។ ផ្ទុយទៅវិញ អ្នកឲ្យគេគប្បីដឹងគុណព្រោះខ្លួនបាននូវ

អ្វីមួយដែលមានតម្លៃលើសប្រាក់ដោយសារស្មមសូមទាន គឺស្ញប់ (រង្វាន់មកពីអល់ឡោះហ៊្ញ عزوجل) ។

ពេលអ្នកណាមួយបន្ទោកតម្លៃខ្លួនឯងដាក់អ្នកដទៃ អ្នកនោះចំអកឲ្យខ្លួនឯងនិងខ្វះសេចក្ដីក្លាហាន ។

អ៊ីម៉ាំ យ៉ាក៏ហ្វារ អាស្វ-ស៍ឌិក្ក صلوات الله عليه والسلام បានអធិប្បាយពន្យល់ថា៖ "ការពិតអល់ឡោះហ៊្ញ عزوجل បានផ្ទេររឿងទាំងអស់ឲ្យទៅអ្នកមានសទ្ធា លើកលែងរឿងបន្ទោកខ្លួនឯងដាក់អ្នកដទៃ ពីព្រោះគេមិនបានថែងនៅក្នុងព្រះគម្ពីរគួរអានទេថា "សេចក្ដីកោតសរសើរបានមកលើអល់ឡោះហ៊្ញ عزوجل បានមកលើព្រះសាស្ដាព្រះអង្គ عزوجل និងបានមកលើបណ្ដាអ្នកសទ្ធា តែពួកមានពុតត្បុតមិនដឹងរឿងនេះទេ" ?"

ច្រើនបុគ្គលក្នុងលោកនេះព្រមបន្ទាបក្បាលដាក់អ្នកដទៃ ព្រោះតែចង់បានអ្វីមួយពីគេ ។ ឧទាហរណ៍ ពេលថៅហ្វាយនាយចំអន់យើងនៅពីមុខអ្នកដទៃ យើងព្រមទទួលដោយមិននិយាយតវ៉ា នេះគឺការបន្ទោកខ្លួនឯងដើម្បីនឹងឲ្យថៅហ្វាយនាយយើងសើចសប្បាយ ។

អល់ឡោះហ៊្ញ عزوجل បានបង្កើតយើងមកស្មើគ្នា ។ ដូច្នេះ បើយើងបន្ទាបក្បាលដាក់អ្នកដទៃព្រោះតែយើងគិតថាអ្នកដទៃគ្រាន់បើជាងយើង ។ បានសេចក្ដីថាបើយើងបន្ទាបក្បាលដើម្បីអំណាចនិងប្រាក់របស់អ្នកដទៃ យើងធ្វើសក្ការៈអ្នកនោះ ។ សរុបសេចក្ដីគឺយើងលើកបុគ្គលទាំងនោះដាក់ស្មើនឹងអល់ឡោះហ៊្ញ عزوجل គេហៅអំពើនេះថាមុស្ចរិក (مُشْرِك - ជឿព្រះច្រើនលើសពីមួយ) ។

**មេរៀនទី ១៥**

# ត្អូញត្អែរពេលមានទុក្ខលំបាក

នេះផ្ទុយពី ស្វ៊ាបារ (صَبْر) ។ វាជាទម្លាប់អាក្រក់មួយ ហើយជាប្រការមួយដែលធ្វើឲ្យយើងឃ្លាតឆ្ងាយពីព្រះមេត្តាប្រណីរបស់អល់ឡោះហ្ស៊ូ ។

ត្អូញត្អែរពេលយើងត្រូវទុក្ខវេទនាចោមរោម សឲ្យឃើញថាយើងមិនទុកចិត្តអល់ឡោះហ្ស៊ូ ។ នេះព្រោះតែអល់ឡោះហ្ស៊ូសាកល្បងយើងដើម្បីនឹងដឹងថាតើយើងមានអំណត់និងចេះស៊ូទ្រាំឬទេ ។

បើយើងព្យាយាមពុះពារបញ្ហាដោយថា "អាល់-ហ្ចាំឌូ លិលឡាស្ស់ អាចធូន់ជាងនេះ" យើងនឹងជោគជ័យក្នុងការល្បងពិសោធន៍នេះ ។

បើយើងមិនតស៊ូដើម្បីពុះពារឧបសគ្គទេ បានតែត្អូញត្អែរដាក់អល់ឡោះហ្ស៊ូថា "ហេតុអ្វីវាធ្លាក់មកលើខ្លួនខ្ញុំ" ឬ "មិនត្រឹមត្រូវទេ" យើងនឹងបរាជ័យក្នុងការល្បងពិសោធន៍ ព្រោះអល់ឡោះហ្ស៊ូមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍អាស្ស៊-ស្សារហ៍ អាយ៉ាស្ស៊ 6 (94:6) ថា៖

إِنَّ مَعَ ٱلْعُسْرِ يُسْرًا ۝٦

*6. មែន សេចក្តីលំបាកនៅជាមួយសេចក្តីស្រណុក ។*

មានន័យថាទោះបីយើងរងការលំបាកប៉ុណ្ណាក៏ដោយនៅក្នុងលោកនេះ បើយើងអត់ធ្មត់ និងព្យាយាមរកមធ្យោបាយដោះស្រាយការលំបាកអស់ពីសមត្ថភាពអល់ឡោះហ្ស៊ូនឹងជួយយើង យើងនឹងបានធូរស្រាលជាមិនខាន ។

ដូច្នេះ បើយើងអត់ធ្មត់ បញ្ហានានានឹងដោះស្រាយបានដោយខ្លួនឯងអាស្រ័យព្រះគុណអល់ឡោះហ្ស៊ូ ។

មនុស្សច្រើនធ្លាប់តែត្អូញត្អែរ ។ ជនទាំងនោះត្អូញអំពីធាតុអាកាសត្រជាក់ក្នុងរដូវរងា អំពីធាតុអាកាសក្តៅក្នុងរដូវក្តៅ ។ ជនទាំងនោះមានលេសត្អូញត្អែរឬរិះគន់ជានិច្ច ។

ប្រការសំខាន់ដែលយើងអាចដកស្រង់បានពីមេរៀននេះគឺ ពេលយើងពើបពះបញ្ហានីមួយ យើងត្រូវខិតខំដោះស្រាយបញ្ហានោះ ។ បើយើងស្មោះមែន

អល់ឡោះហ៍ﷻនឹងជួយយើង ។ អាចប្រើពេលយូរ តែយើងនឹងបានជោគជ័យក្នុងរយៈពេលដ៏យូរនោះបើចិត្តនិងបំណងយើងស្មោះពិត ។

# ការកម្ហេញ

គឺការរំពៃចាប់កំហុសគេ ឬស្តីបន្ទោសគេ ឬត្អូញត្អែរមិនលែង ។

វាជាទម្លាប់អាក្រក់ណាស់ វាអាចធ្វើឲ្យមនុស្សធុញទ្រាន់អ្នក គេចចេញឆ្ងាយពីអ្នក ។

ពេលយើងត្អូញច្រំដែល បានសេចក្តីថាយើងនិយាយដដែលៗមិនឈប់ ។ គេមិនចូលចិត្តទង្វើនេះទេ ។ បើយើងចង់ថាអ្វី យើងត្រូវថាម្តង ។ មិនចាំបាច់ថាច្រើនដងទេ ព្រោះវាធ្វើឲ្យគេជ្រេញចិត្ត ។

បើយើងមានបញ្ហា យើងមិនត្រូវត្អូញត្អែរដាក់គេទេ តែត្រូវសូមជំនួយពីអល់ឡោះហ៍ﷻ ។

កាលព្រះសាស្តាយូស៊ុហ្វعليه السلامត្រូវបងៗចោលទៅក្នុងអណ្តូងទឹក ព្រះបិតាعليه السلامព្រះអង្គعليه السلامកើតទុក្ខខ្លាំងណាស់ ។ ព្រះអង្គعليه السلامមិននៅតែមួយកន្លែង បានតែត្អូញត្អែរទេ ។ ព្រះអង្គعليه السلامបានសារទុក្ខប្រាប់ព្រះមួយគត់ដែលអាចជួយព្រះអង្គعليه السلامបាន គឺអល់ឡោះហ៍ﷻ ។

ស៊ូរ៉ោះត៍ យូស៊ុហ្វ អាយ៉ាស់ 84-86 (12:84-86) ចែងថា៖

وَتَوَلَّىٰ عَنْهُمْ وَقَالَ يَـٰٓأَسَفَىٰ عَلَىٰ يُوسُفَ وَٱبْيَضَّتْ عَيْنَاهُ مِنَ ٱلْحُزْنِ فَهُوَ كَظِيمٌ ﴿٨٤﴾ قَالُوا۟ تَٱللَّهِ تَفْتَؤُا۟ تَذْكُرُ يُوسُفَ حَتَّىٰ تَكُونَ حَرَضًا أَوْ تَكُونَ مِنَ ٱلْهَـٰلِكِينَ ﴿٨٥﴾ قَالَ إِنَّمَآ أَشْكُوا۟ بَثِّى وَحُزْنِىٓ إِلَى ٱللَّهِ وَأَعْلَمُ مِنَ ٱللَّهِ مَا لَا تَعْلَمُونَ ﴿٨٦﴾

*84. គេ (យ៉ាក៉ូប) បានបែរចេញពីពួកគេហើយពោលថា៖ "ឱអនិច្ចា យូស៊ូហ្វអើយ!" ភ្នែកទាំងពីររបស់គេទៅជាសស្លាំងដោយសារកើតទុក្ខ ។ គេបានអត់ធ្មត់សង្កត់ចិត្ត ។ 85. ពួកគេ (បងប្អូនរបស់យូស៊ូហ្វ) បានថា៖ "អល់ឡោះហ៍អើយ លោកឪពុករំឮកដល់យូស៊ូហ្វមិនដាច់ រហូតដល់ឈឺឬស្លាប់ ។" 86. គេ (យ៉ាក៉ូប) បានថ្លែងថា៖ "អញថ្លែងទុក្ខព្រួយរបស់អញប្រាប់អល់ឡោះហ៍ទេ ។ អញដឹងពី*

*អស់ឡោះហ្ ៍អ្វីដែលពួកឯងរាល់គ្នាមិនដឹងទេ ។*

សឲ្យឃើញថាយើងត្រូវត្អូញត្អែរដាក់អល់ឡោះហ្ ﷻ តែមួយគត់ ពេលយើងមានអាសន្ន ។

ច្រើនបុគ្គលត្អូញមិនឈប់ ឬរំអុកឪពុកម្ដាយ ។ ឧទាហរណ៍ ពេលឪពុកម្ដាយប្រាប់ថានឹងទៅធ្វើវនភោជន៍ (ទៅកំសាន្ត បរិភោគអាហារនៅទីឆ្ងាយ) កូនៗខ្លះរំអុកមិនឈប់ថា៖ "កាលណាបានទៅ កាលណាបានទៅ!!"

ពួកកូនៗនោះធ្វើបែបនេះជាញឹកញយ បណ្ដាលឲ្យឪពុកម្ដាយចាំបាច់ត្រូវតែស្ដីឲ្យថា៖ "បើមិននៅស្ងៀមទេ យើងនឹងលែងទៅ ។"

ចូរចងចាំថាពេលគេសន្យាយើងអ្វីមួយ គេនឹងព្យាយាមធ្វើតាមការសន្យានោះអស់ពីសមត្ថភាព ។ មិនចាំបាច់រំលឹកគេច្រើនដងទេ ។ បើយើងរំអុកគេមិនឈប់នឹងធ្វើឲ្យគេរំខានចិត្ត ។

តើអ្នកឃើញមានការត្អូញត្អែរបែបណាទៀតទេ ? តើគេមានអារម្មណ៍យ៉ាងណាបើអ្នកណាមួយត្អូញត្អែរដាក់អ្នក ?

## មេរៀនទី ១៦

# ដណ្ដើមយកទ្រព្យគេ

ដណ្ដើមយកមានន័យថារឹបអូសយកទ្រព្យរបស់អ្នកដទៃ ដោយបង្ខំ ។ ដោយកម្លាំងឬ ជាញឹកញយ ដោយគំរាមកំហែងគេ ។ល ។

ការដណ្ដើមយករបស់គេជាប្រការហ៊ារ៉ាំ ព្រោះវាជាទ្រព្យដែលយើងបានមកដោយអយុត្តិធម៌ដោយបំពារបំពានលើគេ (គឺអ្នកដែលត្រូវគេប្លន់យកទ្រព្យ) ដែលពុំមានសមត្ថភាពការពារខ្លួន ។

បុគ្គលដែលប្រព្រឹត្តអំពើដណ្ដើមយករបស់គេ ប្រើអំណាចនិងទ្រព្យលោកីយដែលអល់ឡោះហ្វ៍ عز وجل ប្រទានឲ្យនោះសម្រាប់យកបាន នូវទ្រព្យឬសិទ្ធិរបស់អ្នកដទៃដែលមិនសម្បូរទ្រព្យដូចខ្លួន ។

ឧទាហរណ៍កសិករពីរនាក់ លោក ក និង លោក ខ ។




កសិដ្ឋាន របស់លោក ក ធំណាស់ ។ គាត់ ចង់យកកសិដ្ឋានរបស់លោក ខ ដើម្បីពង្រីក កសិដ្ឋានគាត់ឲ្យកាន់តែធំឡើង ។

តែលោក ខ មិនព្រមលក់កសិដ្ឋានគាត់ទេ ។ លោក ក ក៏បានសាងសង់ទំនប់ទឹកស្ទឹងពាំងកសិដ្ឋានរបស់លោក ខ ។ បានសេចក្ដីថាកសិដ្ឋានលោក ខ មិនអាចផ្ដល់ទឹកឲ្យសត្វចិញ្ចឹមរបស់គាត់បានទេ មិនអាចស្រោចដំណាំគាត់បានទេ ។ល ។ លោក ខ ក៏ក្ស័យធនចាំបាច់ត្រូវលក់កសិដ្ឋានគាត់ឲ្យលោក ក ។ លោក ក ក៏បានបើកទំនប់ ។

នេះគឺគំរូមួយនៃការដណ្ដើមយកទ្រព្យរបស់អ្នកដទៃ ព្រោះលោក ខ ចាំបាច់ត្រូវបង្ខំចិត្តលក់ដីគាត់ឲ្យគេ ទោះបីគាត់មិនចង់លក់ដីនោះក៏ដោយ ។

ប្រការអាក្រក់បំផុតមួយក្នុងការដណ្ដើមយកពីគេនោះ គឺការដណ្ដើមយកសិទ្ធិរបស់បុគ្គល ។ យើងអាចឃើញបានថានៅឯប្រទេសខ្លះ រដ្ឋាភិបាលមិនផ្ដល់ឲ្យប្រជាពលរដ្ឋនូវសិទ្ធិមនុស្សទេ ដែលអ៊ីស្លាមបានតម្រូវឲ្យមនុស្សទាំងអស់ត្រូវបាននោះ ។

# លួច

លួចជាប្រការហាមឃាត់ ។ មានន័យថាយកអ្វីមួយដែលមិនមែនរបស់យើងដោយមានបំណង (នៀត) មិនឲ្យគេវិញ ។

អ្នកខ្លះថាយើងអាចលួចគេបានបើអ្នកនោះមិនមែនមុស្លីមទេ ។ តើធ្វើបែបនេះត្រឹមត្រូវទេ ? ប្រាកដជាមិនត្រឹមត្រូវទេ !

គេមិនអនុញ្ញាតឲ្យយើងលួចគេឡើយ ទោះបីអ្នកនោះជាមុស្លីមឬមិនមែនក៏ដោយ ។

លួចមិនត្រឹមតែបានសេចក្ដីថាយកអ្វីមួយនោះទេ ។ ជាញឹកញយ ការលួចបានប្រព្រឹតទៅដោយបែបមិនចំៗ ដោយវិធីវាង ។ បើខ្ញុំទិញសំបុត្រមួយដើម្បីជិះរថយន្តពីកន្លែង ក ទៅកាន់កន្លែង ខ ហើយខ្ញុំប្រើសំបុត្រតែមួយនេះដើម្បីទៅកាន់កន្លែង គ ទោះបីខ្ញុំដឹងថាគេមិនអនុញ្ញាតឲ្យខ្ញុំធ្វើបែបនេះទេក៏ដោយ តែនេះគឺការលួចគេ ។ អ្នកខ្លះថាទង្វើនេះមិនចំជាការលួចគេទេ តែវាជាការលួចគេដែរ ។

អ្នកយល់ឃើញយ៉ាងណា អំពីបុគ្គលដែលប្រើសំបុត្រធ្វើដំណើររបស់អ្នកដទៃដើម្បីធ្វើដំណើរ ? តើវាជាការលួចគេទេ ? ចូរអ្នកគិតមើលនិងឲ្យចម្លើយដោយខ្លួនឯង ។

ពេលគេលួចរបស់នីមួយ របស់នោះទៅជា "ក៊ុស្ហ៍ប៊ី (غصب)" (គឺវត្ថុលួចគេ) ។

ឧទាហរណ៍ បើបុរសម្នាក់ កាន់សីលត្រណមអាហារ លួចអាវគេមកពាក់ ។ បន្ទាប់មកគាត់ស្ហ៍ឡាត្ទ៍ដោយពាក់អាវនោះ ។ ពេលយប់គាត់ស្រាយត្រណម តែស្ហ៍ឡាត្ទ៍គាត់និងសីលត្រណមគាត់ត្រូវមោឃៈ ព្រោះអាវគាត់ក៊ុស្ហ៍ប៊ី (ជាវត្ថុលួចគេ) ។

## ហេតុអ្វីលួចគេជាប្រការហ៊ារ៉ាំ?

លួចគេជាប្រការដែលច្បាប់ហាម ព្រោះអ្នកទាញផលប្រយោជន៍ពីអ្នកដទៃដោយធ្វើអ្នកដទៃនោះខាតបង់។ អ្នកយកចំណេញលើការខូចខាតរបស់អ្នកដទៃ។ បើអ្នកណាមួយធ្វើការដើម្បីទទួលបាននូវអ្វីមួយ អ្នកយកអ្វីនោះពីអ្នកនោះ នេះជាអំពើអយុត្តិធម៌ គេហៅទង្វើនេះថាលួចគេ។ ដូច្នេះឯងបានជាលួចគេជាប្រការហ៊ារ៉ាំ។

**មេរៀនទី ១៧**

# គេចវេះភារកិច្ច

គេចវេះភារកិច្ចមានន័យថាបោះបង់អ្វីដែលខ្លួនត្រូវធ្វើជាចាំបាច់ ។

ភារកិច្ចមាន ៣ ប្រការគឺៈ

១. ភារកិច្ចចំពោះអល់ឡោះហ្វ៎عَزَّ وَجَلَّ ។

២. ភារកិច្ចចំពោះមុស្លីម ។

៣. ភារកិច្ចចំពោះមនុស្សជាតិ (រាប់បញ្ចូលខ្លួនឯងដែរ) ។



ឧទាហរណ៍គំរូ នៃការគេចវេះភារកិច្ចចំពោះអល់ឡោះហ្វ៎عَزَّ وَجَلَّនោះ គឺមិនស្ហ្ំឡាត់ ។ នេះជាទង្វើហារ៉ាំ អល់ឡោះហ្វ៎عَزَّ وَجَلَّមិនស្រឡាញ់បុគ្គលបែបនេះទេ ។ បំពេញភារកិច្ចចំពោះអល់ឡោះហ្វ៎عَزَّ وَجَلَّ គឺបំពេញភារកិច្ចលើខ្លួនឯងដែរ ពីព្រោះអ្វីដែលអល់ឡោះហ្វ៎عَزَّ وَجَلَّបញ្ជាឲ្យយើងធ្វើនោះគឺដើម្បីផលប្រយោជន៍យើង ។



ឧទាហរណ៍គំរូ នៃការគេចវេះភារកិច្ចចំពោះមុស្លីមនោះ គឺមិនបញ្ចុះសពអ្នកស្លាប់ ។ ពេលមុស្លីមស្លាប់ វ៉ាយ៉ឹបឲ្យផ្ងូតទឹកម៉ាយិត ត្រូវធានាខុសត្រូវបញ្ចុះសពមុស្លីមនោះ តាមច្បាប់អ៊ីស្លាម ។ បើមិនបានធ្វើដូច្នេះទេ បណ្ដាអ្នកដែលបានដឹងអំពីការស្លាប់នោះ នឹងមានទោសចំពោះអល់ឡោះហ្វ៎عَزَّ وَجَلَّ នឹងមានបាប (គូណាស្ហ៊) ។

ឧទាហរណ៍គំរូនៃការគេចវេះភារកិច្ចចំពោះមនុស្សជាតិ គឺបំផ្លិចបំផ្លាញអ្វីដែលអ្នកដទៃត្រូវការប្រើប្រាស់ ។ ឧទាហរណ៍អ្នកមានកសិដ្ឋាននៅមាត់ស្ទឹង ជីនិងសារធាតុគីមីឯទៀតរបស់អ្នកធ្វើឲ្យខូចទឹកស្ទឹងនោះ ។ ទឹកខូចនេះប៉ះពាល់ដល់ប្រជារាស្ត្រដែលនៅខាងក្រោមស្ទឹងដែលយកទឹកនេះមកបរិភោគ ។ វាជាកាតព្វកិច្ចរបស់អ្នកដែលមិនធ្វើឲ្យទឹកស្ទឹងនេះខូច ទោះបីអ្នកប្រើទឹកនេះជាមុស្លីមក្តី មិនមែនមុស្លីមក្តី ជាមិត្តក្តី ជាសត្រូវក្តី ។

អ៊ីស្លាមជាសាសនាសម្រាប់សត្វលោកទាំងអស់ ដែលបើកសិទ្ធិឲ្យសព្វសារពើ ។ សត្វលោកនីមួយៗ ទោះជារុក្ខជាតិក្តី សត្វក្តី មនុស្សក្តី សុទ្ធតែមានសិទ្ធិកំណត់ដោយអ៊ីស្លាម យើងត្រូវចេះអនុវត្តិនិងគោរពសិទ្ធិទាំងនេះ ។

## មេរៀនទី ១៨

# ការសូកប៉ាន់

សូកប៉ាន់គេ មានន័យថាជះឥទ្ធិពលទៅលើការសម្រេចចិត្តរបស់អ្នកនោះ ដោយឲ្យប្រាក់អ្នកនោះឬវត្ថុមានតម្លៃ ។

ការសូកប៉ាន់ជាបាបធំមួយ ត្រូវសាសនាអ៊ីស្លាមផ្ដន្ទាទោស ។

អ៊ីម៉ាំអាលីﷺមានវចនៈថា៖ "អល់ឡោះហ៍ﷻដាក់បណ្ដាសាអ្នកសូកប៉ាន់ អ្នកទទួលសំណូក (អ្នកស៊ីសំណូក) និងអ្នកបើកដៃឲ្យមានការសូកប៉ាន់ ។"

មូលហេតុដែលអល់ឡោះហ៍ﷻហាមយើងសូកប៉ាន់នោះ គឺវាមិនយុត្តិធម៌និងមិនសុចរិត ។

ឧទាហរណ៍មានបុគ្គលម្នាក់លួចប្រាក់ក្រុមហ៊ុន ។ បើមានបុគ្គលម្នាក់ទៀតឃើញគេលួចប្រាក់ គាត់អាចទៅប្ដឹងអាជ្ញាធរនគរបាល ។ តែបើចោរប្រាប់បុគ្គលនោះថា៖"ចូរកុំប្រាប់គេខ្ញុំនឹងជូនលោកនូវប្រាក់នោះមួយចំណែក ។" បានសេចក្ដីថាបុគ្គលទីពីរប្ដូរចិត្តវិញ គាត់មិនប្ដឹងនគរបាលទេ បែរមកជួយចោរឲ្យរត់រួចខ្លួន (ពោលគឺ គេបង្វិលខួរក្បាលគាត់បាន) ។

នេះគឺការស៊ីសំណូក ។ វាជាអំពើហ្ារ៉ាំ ព្រោះបុគ្គលនោះបណ្ដោយឲ្យប្រាក់ឬទ្រព្យសម្បត្តិបង្វែរបង្វិលចិត្តគាត់បាន គាត់មិនបណ្ដោយឲ្យសតិអារម្មណ៍ឬសម្បជញ្ញៈគាត់បង្វែរបង្វិលចិត្តគាត់ទេ ។

បើប្រការណាមួយត្រឹមត្រូវ អ្នកត្រូវធ្វើប្រការនោះដោយមិនអើពើអំពីអ្នកដទៃថាឬគិតនោះទេ ។ បើប្រការណាមួយមិនត្រឹមត្រូវទេ អ្នកមិនត្រូវធ្វើប្រការនោះទេ ទោះបីគេឲ្យប្រាក់អ្នកច្រើនប៉ុណ្ណាក៏ដោយ ដើម្បីនឹងឲ្យអ្នកធ្វើប្រការមិនត្រឹមត្រូវនោះ ។ ចូរកុំបណ្ដោយឲ្យអ្វីមួយឬអ្នកណាមួយបង្វែរបង្វិល ឬធ្វើឲ្យចិត្តគំនិតអ្នកលំអៀងចេញពីសច្ចៈធម៌បានឡើយ ។

បុគ្គលដែលទទួលសំណូក (ដែលស៊ីសំណូក) ត្រូវអល់ឡោះហ៊្ ដាក់បណ្ដាសាព្រោះបុគ្គលនោះ "លក់" សម្បជញ្ញៈនិងសតិអារម្មណ៍ខ្លួនឯងដើម្បីលោកនេះ បានសេចក្ដីថាក្នុងលោកមុខបុគ្គលនោះនឹងនៅក្នុងចំណោមបណ្ដាអ្នកបរាជ័យ ។

អ្នកអាចលើកឧទាហរណ៍គំរូសំណូកច្រើនបែបទៀតបានទេ ?

# ព្រឹទ្ធិកម្ម

ព្រឹទ្ធិកម្មមានន័យថាដាក់ការប្រាក់ច្រើនហួសពេក ។

យើងទាំងអស់គ្នាដឹងស្រាប់ហើយថាស៊ីការប្រាក់ជាប្រការហ៊ារ៉ាំ ក្នុងគ្រប់ករណី ។

ការប្រាក់មានន័យថាពេលអ្នកឲ្យប្រាក់គេខ្ចី អ្នកដាក់កំណត់ឲ្យអ្នកនោះបង់ប្រាក់ថែមពេលអ្នកនោះយកប្រាក់មកសងអ្នកវិញ ។

ឧទាហរណ៍ អ្នកឲ្យប្រាក់ខ្ញុំខ្ចី ១០ រៀល ពេលខ្ញុំយកប្រាក់មកសងអ្នកវិញ អ្នកនឹងសូមឲ្យខ្ញុំសងវិញ ១១ រៀល បានសេចក្ដីថាស្មើនឹងការប្រាក់ ១០% ។ នេះគឺប្រការហ៊ារ៉ាំ ។

ព្រឹទ្ធិកម្មមានន័យថាដាក់កំណត់ការប្រាក់ច្រើនហួសពេក ។

ឧទាហរណ៍ អ្នកឲ្យប្រាក់ខ្ញុំខ្ចី ១០ រៀល ពេលខ្ញុំសងអ្នកវិញ អ្នកនឹងសូមឲ្យខ្ញុំសង ១៦ រៀល ។ នេះគឺព្រឹទ្ធិកម្ម ព្រោះអត្រាការប្រាក់លើកនេះឡើងដល់ ៦០% ។

អល់ឡោះហ៊្ មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 275 (2:275) ថា៖

ٱلَّذِينَ يَأْكُلُونَ ٱلرِّبَوٰاْ لَا يَقُومُونَ إِلَّا كَمَا يَقُومُ ٱلَّذِى يَتَخَبَّطُهُ ٱلشَّيْطَٰنُ مِنَ ٱلْمَسِّ ۚ ذَٰلِكَ بِأَنَّهُمْ قَالُوٓاْ إِنَّمَا ٱلْبَيْعُ مِثْلُ ٱلرِّبَوٰاْ ۗ وَأَحَلَّ ٱللَّهُ ٱلْبَيْعَ وَحَرَّمَ ٱلرِّبَوٰاْ ۚ ... ﴿٢٧٥﴾

*275. បណ្ដាអ្នកដែលស៊ីព្រឹទ្ធិកម្ម (គឺយកចំណេញច្រើនពេក) នឹងក្រោកឈរបានដូចពួកឡប់ស្មារតីដោយសារតែស្ទៃតួនប៉ះពាល់ ។ នោះព្រោះពួកគេថា៖ "ការលក់ដូរស្រដៀងព្រឹទ្ធិកម្មដែរ ។" អល់ឡោះហ៍បានអនុញ្ញាតឲ្យលក់ដូរ តែព្រះអង្គបានហាមព្រឹទ្ធិកម្ម (យកចំណេញច្រើនពេក) ។*

នៅក្នុងស៊ូរ៉ោះតុ៏ អាល់-បាក៏រ៉ោះតុ៏ អាយ៉ាស៊ូ 278-279 (2:278-279) ថា៖

يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ ٱتَّقُواْ ٱللَّهَ وَذَرُواْ مَا بَقِىَ مِنَ ٱلرِّبَوٰٓاْ إِن كُنتُم مُّؤْمِنِينَ ﴿٢٧٨﴾ فَإِن لَّمْ تَفْعَلُواْ فَأْذَنُواْ بِحَرْبٍ مِّنَ ٱللَّهِ وَرَسُولِهِۦ ۖ وَإِن تُبْتُمْ فَلَكُمْ رُءُوسُ أَمْوَٰلِكُمْ لَا تَظْلِمُونَ وَلَا تُظْلَمُونَ ﴿٢٧٩﴾

*278. បណ្ដាអ្នកមានសទ្ធាអើយ ចូរខ្លាចក្រែងអល់ឡោះហ៍[ដោយអធិមោក្ខ] ។ ចូរពួកអ្នកលះបង់ចោលព្រឹទ្ធិកម្មដែលនៅសេសសល់ បើពួកអ្នកមានសទ្ធាជ្រះថ្លា ។*
*279. បើពួកអ្នកមិនធ្វើ[តាមបញ្ជានោះ]ទេ ចូរពួកអ្នកដឹងខ្លួនទុកជាមុនចុះថានឹងមានសង្គ្រាមពីអល់ឡោះហ៍និងសាស្ដារបស់ព្រះអង្គ ។ បើពួកអ្នកស្មារលោលែងធ្វើទៀត ពិតណាស់ ពួកអ្នកនឹងបានដើមទុនរបស់ពួកអ្នក ។ ពួកអ្នកកុំប្រព្រឹត្តអំពើអយុត្តិធម៌លើអ្នកណាមួយ ហើយគេក៏កុំប្រព្រឹត្តអំពើអយុត្តិធម៌លើពួកអ្នក ។*

## ហេតុអ្វីព្រឹទ្ធិកម្មជាប្រការហារ៉ាំ ?

មូលហេតុមួយដែលព្រឹទ្ធិកម្មជាប្រការហារ៉ាំនោះ គឺព្រោះអ្នកទាញយកផលប្រយោជន៍ពីបណ្ដាអ្នកដែលក្រជាងអ្នក ។

សព្វសារពើដែលអ្នកមានដូចជាប្រាក់ មាស សំលៀកបំពាក់ឬទ្រព្យផ្សេងៗទៀតជាដើម សុទ្ធតែមកពីអល់ឡោះហ៍ﷻ អ្នកត្រូវអរព្រះគុណព្រះអង្គﷻ ។ តើព្រះអង្គﷻកំណត់ការប្រាក់មកលើអ្នកទេ ពេលព្រះអង្គﷻព្រះរាជទានអ្វីៗទាំងនេះឲ្យអ្នកនោះ ?

ព្រោះតែទ្រព្យទាំងនេះត្រូវប្រទានឲ្យអ្នក អ្នកមិនមានសិទ្ធិឲ្យគេខ្ចីទ្រព្យទាំងនេះដោយដាក់ការប្រាក់ទេ ព្រោះវាជាប្រការល្មោភ ។

## មេរៀនទី ១៩

# ការបោកប្រាស់

បោកប្រាស់គឺបានមកនូវអ្វីមួយដោយឆបោកគេ ។

ការបោកប្រាស់ជាប្រការហ៊ារ៉ាំ ។

បោកប្រាស់មានច្រើនបែប ឧទាហរណ៍៖

ក. លាក់មិនឲ្យគេដឹងថារបស់ដែលខ្លួនលក់ឲ្យគេនោះមានកំហូច ។

ខ. ចម្លងតាមគេពេលប្រលង ។

គ. ខ្ចីប្រាក់គេ មិនសងគេវិញសោះ ។

ឃ. ដើរប្រមូលប្រាក់ដើម្បីធ្វើបុណ្យទាន រួចហើយប្រើប្រាក់នោះសម្រាប់ខ្លួនឯង ។

គេថា "ដើម្បីបានសម្រេចត្រូវប្រើគ្រប់មធ្យោបាយ" បានសេចក្ដីថាមិនសំខាន់ទេមធ្យោបាយដែលអ្នកប្រើនោះ ឲ្យតែបានលទ្ធផលល្អ ។

អ៊ីស្លាមមិនឲ្យធ្វើបែបនេះទេ ។ បើអ្នកចាំបាច់ត្រូវឆបោកដើម្បីធ្វើអំពើល្អ ចូរកុំធ្វើទង្វើល្អនោះ ។

ឧទាហរណ៍ ខ្ញុំចង់បរិច្ចាគប្រាក់ឲ្យទៅម៉ាស់យ៊ីដ្ ។ ដូច្នេះ ខ្ញុំដើរប្រមូលប្រាក់ពីអ្នកស្រុកដោយប្រាប់គេថាខ្ញុំកំពុងជួបប្រទះការលំបាក ខ្វះខាតប្រាក់ ។ រួចហើយ ខ្ញុំបរិច្ចាគប្រាក់ប្រមូលបាននោះឲ្យទៅម៉ាស់យ៊ីដ្ ។ តើខ្ញុំនឹងទទួលបានផលបុណ្យទេ (ស្វាវ៉ាប់) ? ចម្លើយគឺ**ទេ** ។ ជំនួសផលបុណ្យ (ស្វាវ៉ាប់) ខ្ញុំនឹងបានបាបដោយសារតែខ្ញុំបានបោកប្រាស់គេ ។

ចូរដឹងអំពីការបោកប្រាស់ថា ទោះបីអ្នកអាចបោកប្រាស់គេបានច្រើននាក់ក៏ដោយ ដោយប៉ិនប្រសប់យ៉ាងណាក៏ដោយ តែអ្នកមិនអាចឆបោកខ្លួនឯងឬបោកប្រាស់អល់ឡោះហ៊្វ ﷻ បានជាដាច់ខាត ។ បើអ្នកបោកប្រាស់អ្នកណាម្នាក់ សម្បជញ្ញៈរបស់អ្នក (គឺប៉ែកល្អរបស់ណាហ្វ៍ស៍អ្នក) នឹងដឹងភ្លាម ។

អ្នកខ្លះថាបោកប្រាស់គេបាន បើអ្នកនោះមិនមែនមុស្លីមទេ ។ នេះគឺ

**សម្ដីភ្លីភ្លើ**! ទាំងអស់គ្នាសុទ្ធតែមានសិទ្ធិរៀងៗខ្លួន ច្បាប់ហាមបោកប្រាស់គេដោយរើសអើងសិទ្ធិគេ ទោះបីគេជាអ្នកណាក៏ដោយ ទោះបីគេជឿសាសនាអ្វីក៏ដោយ ។

មូលហេតុដែលបោកប្រាស់គេជាប្រការហាមឃាត់នោះគឺព្រោះតែ៖

ក. អ្នកបានមកនូវអ្វីមួយដោយបំពារបំពានលើគេ ។

ខ. អ្នកបានមកនូវអ្វីមួយដោយពុំបានខិតខំធ្វើការដើម្បីអ្វីនោះទេ ។

អ៊ីស្លាមតឹងរ៉ឹងណាស់អំពីយុត្តិធម៌ ។ បើអ្នកចង់បានអ្វីមួយដែលល្អ ត្រូវបានអ្វីនោះមកតាមរយៈទង្វើដៃអ្នក មិនមែនបានវាមកដោយធ្វើឲ្យអ្នកដទៃខូចខាតទេ ។

# ការគៃបន្លំ (យកទ្រព្យគេ)

មានន័យថាបោកបញ្ឆោតគេដោយប្រព្រឹត្តអំពើបន្លំលួចនីមួយ ឬបន្លំយកប្រាក់គេដោយការឆបោកដើម្បីយកមកប្រើសម្រាប់ខ្លួនឯង ។

នេះជាទង្វើទូទៅនៅក្នុងអង្គការធំៗ ជាពិសេសនៅក្នុងពិភពលោកសព្វថ្ងៃនេះដែលមានមនុស្សតិចណាស់ប្រព្រឹត្តតាមសីលធម៌ ។ ទោះបីនៅក្នុងករណីនេះក៏ដោយ បុគ្គលដែលប្រព្រឹត្តខុសនោះស្គាល់ទង្វើខ្លួនឯង សម្បជញ្ញៈរបស់បុគ្គលនោះបានដាស់តឿនបុគ្គលនោះឲ្យដឹងការខុសឆ្គងដែលខ្លួនកំពុងធ្វើ បុគ្គលនោះនឹងបិទមាត់ខ្លួនឯង នឹងខ្ទប់សម្បជញ្ញៈខ្លួនឯងដោយថាគេអនុញ្ញាឲ្យធ្វើបែបនេះបានក្នុងធុរកិច្ច ព្រោះធុរកិច្ចត្រូវគ្រប់គ្រងដោយវិធីផ្សេងៗ ។

ការបន្លំយករបស់គេជាប្រការហាមឃាត់ដោយមានមូលហេតុច្រើន ដូចជាការបានមកនូវអ្វីមួយដែលមិនត្រឹមត្រូវដោយធ្វើឲ្យអ្នកដទៃខូចខាតជាដើមនោះ ជាប្រការសំខាន់បំផុតមួយ ។

យើងត្រូវចងចាំជានិច្ចថា ទោះបីយើងធ្វើអ្វីក៏ដោយ អល់ឡោះហ្ជ័ល ﷻ ជាសាក្សីជានិច្ច ព្រះអង្គ ﷻ មើលយើង ។ យើងមិនត្រូវធ្វើអំពើដែលច្បាប់ហាមទេដោយមានមូលហេតុផ្សេងៗ ដូចជា តាក់វ៉ា (تقوى ខ្លាចធ្វើឲ្យអល់ឡោះហ្ ﷻ ទាស់ចិត្ត) ខ្លាចថ្ងៃ

ជំនុំជម្រះជាដើម (អល់ឡោះហ្ជ័ﷻមិនឃោរឃៅទេ បើព្រះអង្គﷻចង់ ព្រះអង្គﷻនឹងអត់ឱនឲ្យចំពោះបាបដែលបានប្រព្រឹត្តដោយអចេតនា ឬចំពោះបាបដែលយើងស្តាយក្រោយនិងរាងចាល តែព្រោះតែព្រះអង្គﷻប្រកបដោយយុត្តិធម៌ តើយើងសង្ឃឹមថាព្រះអង្គﷻនឹងលើកទោសឲ្យយើងបានដូចម្តេច ដែលយើងបានប្រព្រឹត្តលើអ្នកដទៃនោះ (ដរាបណាអ្នកដទៃនោះមិនបានលើកទោសឲ្យយើងទេ) ?)

## មេរៀនទី ២០

# មើលស្ត្រីនិងបុរសដែលត្រូវហាម (មិន-ម៉ាស្ហ៊ុរ៉ម)

អ៊ីស្លាមឲ្យតម្លៃទៅលើសីលធម៌និងសេចក្ដីគោរពសាសនាណាស់ ។ ហ៊ីយ៉ាប់ (حِجَاب) បង្ហាញនូវសារសំខាន់របស់រឿងនេះ ។

ហ៊ីយ៉ាប់មិនបានសេចក្ដីថាស្លៀកពាក់ខ្មៅឬទទូរក្បាលតែម្យ៉ាងទេ ។ ហ៊ីយ៉ាប់ជារបាំងមួយបែបដែលការពារស្ត្រីក៏ដូចបុរសដែរពីការសម្លឹងមើលគ្នា ដែលជួយរក្សាសេចក្ដីថ្លៃថ្នូររបស់បុគ្គលទាំងពីរភេទ ។ ដោយសារហ៊ីយ៉ាប់មនុស្សប្រុសនិងមនុស្សស្រីអាចនិយាយរកគ្នាបានក្នុងឋានៈស្មើគ្នា (ដោយគ្មានគំនិតលាក់បាំង) ព្រោះបុរសនឹងមិនត្រូវសម្រស់នារីបំបែរអារម្មណ៍ទេ ហើយនៅឃ្លាតពីនារីមួយអន្លើដើម្បីផ្ដោតអារម្មណ៍ទៅលើសម្ដីនាង ។ ការពិត ហ៊ីយ៉ាប់របស់ស្ត្រីជួយឲ្យបុរសដាក់ភ្នែក ។

ហ៊ីយ៉ាប់មានពីរប្រការ ។ ប្រការទីមួយសម្រាប់បុរសនិងស្ត្រី ជាថ្នាក់សំខាន់បំផុត គឺដាក់ភ្នែក ។ បានសេចក្ដីថាបុរសមិនត្រូវសម្លឹងមើលស្ត្រីណាដែលមិន-ម៉ាស្ហ៊ុរ៉ម (ដែលត្រូវហាម) សម្រាប់ខ្លួនទេ ។ នេះមិនបានសេចក្ដីទេថាគេមិនអនុញ្ញាតឲ្យអ្នកមើលស្ត្រីឬនិយាយជាមួយស្ត្រីនោះទេ តែបានសេចក្ដីថាអ្នកត្រូវរក្សាខ្សែភ្នែកអ្នកនៅក្នុងព្រំដែននៃសេចក្ដីសមរម្យនិងការខ្លាចបាប ពោលគឺ អ្នកមិនត្រូវសម្លឹងមើលមុខស្ត្រីមិនដាក់ភ្នែកនោះទេ អ្នកត្រូវចៀសវាងសម្លឹងចំខ្សែភ្នែកស្ត្រី ។

ប្រការទីពីរសម្រាប់តែស្ត្រី គឺបិទបាំងសក់និងស្លៀកពាក់រលុង កុំឲ្យរឹបដើម្បីនឹងកុំឲ្យចេញរាងរបស់ខ្លួនប្រាណ ។

ព្រះសាស្ដាមូហ៊ាំម៉ាដ្ ﷺ មានព្រះវចនៈថា៖ "ការសម្លឹងមើលលើកដំបូងបានមកខ្លួនលោក ការសម្លឹងមើលលើកទីពីរប្រឆាំងខ្លួនលោក ។"

មានន័យថាពេលអ្នកសម្លឹងមើលអ្វីមួយ ពោលគឺស្ត្រីគ្មានហ៊ីយ៉ាប់ ឬអ្វីដែលហ៊ារ៉ាំ ការសម្លឹងមើលលើកដំបូងសម្រាប់ខ្លួនអ្នកដើម្បីនឹងឃើញថានោះគឺអ្វី ដើម្បី

អ្នកនឹងដឹងថាអ្វីនោះល្អឬអាក្រក់ ។ បើវាអាក្រក់ហើយអ្នកសម្លឹងមើលម្តងទៀត វាប្រឆាំងនឹងខ្លួនអ្នកព្រោះអ្នកបានធ្វើប្រការអាក្រក់ (គឺសាងបាប) ។

ព្រះសាស្តាអ៊ីសាﷺមានព្រះវចនៈថា៖ "សម្លឹងមើលស្ត្រីដោយល្មោភចង់បាន គឺប្រព្រឹត្តអំពើខុសច្បាប់ផ្លូវភេទជាមួយស្ត្រីនោះនៅក្នុងចិត្តលោក ។

សឲ្យឃើញថាសម្លឹងមើលស្ត្រីដោយតណ្ហា ជាកំហុសមួយដែលអាចចៀសវាងបាន ។ អ្នកមិនអាចនិយាយបានទេថាអ្នកចូលចិត្តទិដ្ឋភាព ពីព្រោះបំណងអ្នកខូច (គឺមានបំណងអាក្រក់ផ្ទុយពីមាត់ថា) ។

ហេតុអ្វីគេហាមសម្លឹងមើលស្ត្រីមិន-ម៉ាស៊្រម ? អល់ឡោះហ៍ﷻមានព្រះបន្ទូលប្រាប់យើងថាដើម្បីអាចចូលឋានសួគ៌បានយើងត្រូវចេះគ្រប់គ្រងពីរប្រការគឺ៖

ក. ចំណង់បរិភោគរបស់យើង (អ្វីដែលយើងបរិភោគ) ។

ខ. តណ្ហាយើង (អ្វីដែលណាហ្វ៍ស៍យើងចង់)

យើងគ្រប់គ្រងចំណង់បរិភោគរបស់យើង ដោយអត់ធ្មត់បរិភោគចំណីហ្ការ៉ាំ ។ ដូចគ្នាដែរ យើងគ្រប់គ្រងណាហ្វ៍ស៍យើងដោយអត់ធ្មត់និងចៀសវាងទិដ្ឋភាពហ្ការ៉ាំ ។

ចំណីហ្ការ៉ាំអាក្រក់សម្រាប់ខ្លួនប្រាណយើង ទិដ្ឋភាពហ្ការ៉ាំអាក្រក់សម្រាប់វិញ្ញាណយើង ។

វិញ្ញាណប្រៀបបាននឹងទឹកថ្លាបរិសុទ្ធ អ្វីដែលផ្ទុកទឹកនោះ (ខ្លួនប្រាណយើង) ប្រៀបបាននឹងថូ ។ អ្វីដែលយើងមើលឃើញតាមភ្នែកយើងចូលទៅក្នុងទឹកវិញ្ញាណយើង ។ បើយើងមើលអ្វីដែលអាក្រក់ យើងនឹងធ្វើឲ្យទឹកខូច (ធ្វើឲ្យកខ្វក់) ដូច្នេះវិញ្ញាណយើងនឹងទៅជាកខ្វក់ វានឹងនាំឲ្យធ្វើអំពើអាក្រក់លើសនោះ ។

យើងត្រូវរក្សាវិញ្ញាណឲ្យជ្រះស្អាតចាកមន្ទិល ដោយអនុញ្ញាតឲ្យតែអ្វីដែលស្អាតប៉ុណ្ណោះចូលទៅក្នុងវិញ្ញាណយើង ។

មិនត្រឹមតែបុរសទេ ដែលត្រូវចៀសវាងទំនាក់ទំនងជាមួយស្ត្រីណាដែលមិនមែនគ្រួសារខ្លួននោះ តែស្ត្រីក៏ត្រូវចៀសវាងទំនាក់ទំនងបែបនេះដែរជាមួយបុរសទោះបីនៅឯសាលារៀនក្តី នៅឯសាកលវិទ្យាល័យក្តីឬតាមផ្លូវក្តី ។

ពេលមនុស្សពីរនាក់នៅជុំគ្នា ស្ហៃតន لعنه الله មកចូលរួមជាបុគ្គលទីបីយ៉ាងរហ័ស ហើយវា لعنه الله ចាប់ផ្តើមចុះដៃធ្វើផែនការអាក្រក់របស់វា لعنه الله ។

*sources:*
www.saba-igc.org
shia974.fr
www.madressa.net

អ៊ីម៉ាំមេម៉ាស្ហាប់ទាំង ៤ ។

| ឈ្មោះអ៊ីម៉ាំមេម៉ាស្ហាប់ | ម៉ាស្ហាប់ | ថ្ងៃកំណើត/ថ្ងៃស្លាប់ សករាជហ៊ិច្ច្រ៉ោះត៍ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ្រិស្តសករាជ |
|---|---|---|---|
| អាប៊ូ ហ្ពានីហ្វាស្ហ៍ | ហ្ពាណាហ្វី | 80-150 ស.ហ. | 699-767 គ.ស. |
| ម៉ាលិក | ម៉ាលីគី | 93-179 ស.ហ | 711-795 គ.ស. |
| អាស្ហ៍-ស្ហាហ្វីអ៊ី | ស្ហាហ្វីអ៊ី | 150-204 ស.ហ | 767-820 គ.ស. |
| អាស្ហ៍ម៉ាដ្ហ៍ ហ្ពាន់បាល់ | ហ្ពាន់បាលី | 164-241 ស.ហ. | 780-855 គ.ស. |

ព្រះសាសា មូហ្ពាំម៉ាដ្ហ៍ ប្រសូត/ចូលព្រះទិវង្គត ឆ្នាំ 570-632 គ.ស.

អ៊ីម៉ាំអ្នកស្នងព្រះសាស្តាមូហ្ពាំម៉ាដ្ហ៍ﷺទាំង ១២ ។

| លំដាប់ | ឈ្មោះ | ឈ្មោះក្រៅ | ឋានន្តរស័ក្តិ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ.ស./ស.ហ. |
|---|---|---|---|---|
| 1 | អាុលី | អាប៊ូ អាល់-ហ្ពាសាន់ | អាមីរុល-មុមីនីន | 600-661/23 មុន ស.ហ.-40 |
| 2 | ហ្ពាសាន់ | អាប៊ូ មូហ្ពាំម៉ាដ្ហ៍ | អាល់-មុច្ចតាបា | 625-670/3-50 |
| 3 | ហ្ពូសៃន៍ | អាប៊ូ អាុប់ឌុលឡោះហ្វ៍ | សៃយីដ្ហ៍ អាស្ហ៍-ស្ហ៊ូហាដាអ៍ | 626-680/4-61 |
| 4 | អាុលី ប៊ិន ហ្ពូសៃន៍ | អាប៊ូ មូហ្ពាំម៉ាដ្ហ៍ | អាស់-សាច្ចយ៉ាដ្ហ៍ ស្សៃនុល-អាប៊ីឌីន | 659-713/38-95 |
| 5 | មូហ្ពាំម៉ាដ្ហ៍ អាល់-បាក្ញេីរ | អាប៊ូ យ៉ាក្ហ៍ហ្វារ | បាក្ញេីរ អាល់-អ៊ូលូម | 676-733/57-114 |
| 6 | យ៉ាក្ហ៍ហ្វារ | អាប៊ូ អាុប់ឌុលឡោះហ្វ៍ | អាស្ហ៍-ស្ហ៍ឌិក្ហ | 702-765/83-148 |
| 7 | មូសា ប៊ិន យ៉ាក្ហ៍ហ្វារ | អាប៊ូ អាល់-ហ្ពាសាន់ | អាល់-កាស្ហ៊ីម | 745-799/128-183 |
| 8 | អាុលី ប៊ិន មូសា | អាប៊ូ អាល់-ហ្ពាសាន់ | អារ-រីដ្ហ៍ | 765-819/148-203 |
| 9 | មូហ្ពាំម៉ាដ្ហ៍ ប៊ិន អាុលី | អាប៊ូ យ៉ាក្ហ៍ហ្វារ | អាត់-តាគ្គី អាល់-យ៉ាវ៉ាដ្ហ៍ | 811-835/195-220 |
| 10 | អាុលី ប៊ិន មូហ្ពាំម៉ាដ្ហ៍ | អាប៊ូ អាល់-ហ្ពាសាន់ | អាល់-ហ្វាឌី អាន់-ណាគ្គី | 828-868/212-254 |
| 11 | ហ្ពាសាន់ ប៊ិន អាុលី | អាប៊ូ មូហ្ពាំម៉ាដ្ហ៍ | អាល់-អាុស់ការី | 846-874/232-260 |
| 12 | មូហ្ពាំម៉ាដ្ហ៍ ប៊ិន ហ្ពាសាន់ | អាប៊ូ ក្ហ៍ស៊ីម | អាល់-ម៉ាស្ហ៍ឌី អាល់-ហ៊ុច្ចយ៉ាស្ហ៍ ស្ហ៍ហ្វ៊ីប អាល់-ស្សាម៉ាន អាល់-ក្ហ៍អ៊ីម | 869/255 |